CEN
CAMBODIA EXPRESS NEWS

# សែនស្តាយផ្កាល់ស្តាំ

និពន្ធដោយ

**គន្ធ ប៊ុនឈឿន**

~១~

## អាគកមាន់ស្រែ មីចែមាន់ស្រុក

**បង** អូនមិនហៅ ! ហៅតែឈ្មោះ
**ជី** វិតស្ម័គ្រស្មោះសម្រស់ចិត្ត
**ដូន** តាតែមួយព្រួយអាណិត
**មួយ** គួរពីរគិតបីកសាង

សែនឆ្អែតចិត្តជាកូនប្រុសតែមួយ ថ្លើមត្រួយពូសុខ ដែលជាអ្នកស្រែទាំងស្បែកទាំងឈាមទាំងនាមទាំងរូប... ។

ក្នុងជាតិនេះធម្មជាតិបានផ្តល់ឱ្យពូសុខ ជាមនុស្សម្នាក់ចេះថ្លឹងរែក ញែករែកពន់ធ្ងន់ស្រាល មានខួរក្បាលជាមនុស្សមិនលឿនហួសចន្ទោល មិនបោកហួសកន្លោស។ គាត់យល់ដូចអ្នកផងដែរថា មានតែវិជ្ជាទេដែលអាចជួយមនុស្សឱ្យផុតពីនរកទៅកាន់ឋានសួគ៌បាន ។

ដោយយល់ច្បាស់យ៉ាងនេះហើយ ទើបគាត់មិនញញើតអ្វីនិងបញ្ជូនកូនគាត់ឱ្យទៅក្រេបទឹកដមវិជ្ជា តាំងពីថ្នាក់កាន់ក្តារឈ្នួន រហូតដល់ថ្នាក់កាន់សៀវភៅធំនោះឡើយ ដែលផ្ទុយស្រឡះពីរូបគាត់កាលនៅពីតូចឪពុកម្តាយ គាត់បែរជាចូលចិត្តចងសក់ជុកឱ្យគាត់ជាប់តែនិងកន្ទុយគោ... ឃ្វាលគោ !... ឃ្វាលក្របី! ... គួថឡើងក្រិនដូចគួថស្វា ស្នាឡើងផ្លែដូចច្រមុះក្តាន់ទៅវិញ ។ បើកុំតែគាត់ឆ្លៀតលួចរៀនពីគេពីឯងនៅពេលដែលគោរវល់ស៊ីសៅម្តង១ ម្ល៉េះសមមកដល់ឥឡូវគាត់ច្បាស់ជាក្លាយទៅជាមនុស្សម្នាក់ដែលមិនចេះ (នខ្វាក់) អ្វីទាល់តែសោះ ។

... ឆ្នាំ១៩៦៨នេះ យុវជនសែនឆ្អែតចិត្តបានឈោងមកដល់ថ្នាក់ទី៤ ទំនើបជាតិ ក្នុងអនុវិទ្យាល័យស្គន់នេះហើយ ។ គេជាយុវជនភ្នែកបួន (គឺពាក់ វ៉ែនតាតាំងពីនៅរៀន) ដែលមានប្រជាប្រិយភាពជ្រួតជ្រាបលើបេះដូងមិត្តរួមថ្នាក់ទូទៅ មិនតែប៉ុណ្ណោះជាទីស្រឡាញ់រាប់អានរបស់ញាតិមិត្តជាប់របងទៀតផង ។

ចិត្តជាកូនអ្នកស្រែពិត ពេលវ៉ាកងគឺវ៉ាកង គេមិនដែលរៀន (គួរ) បន្ថែមទៀតទេ ព្រោះគេយល់ថា (ពេលរៀនបែរទៅជាឈប់ហើយពេលឈប់បែរទៅជារៀន)

នោះមិនសមសួនតាមក្រឡាជីវិតសិក្សាឡើយ ។

តាំងពីចូលថ្នាក់ទី៤ រហូតមកដល់ពាក់កណ្តាលឆ្នាំនេះ ចិត្តដូចជាមានអម្រែកការសិក្សាធ្ងន់ជាងឆ្នាំមុន១មែន ! មកពីគេធ្លាប់និយាយប្រាប់ពូសុខថា ឆ្នាំនេះនឹងខំយ៉ាងណាឱ្យបានពិន្ទុល្អបំផុតពីមណ្ឌលប្រឡង ។

... រសៀលត្រជាក់នៃថ្ងៃអាទិត្យ ។

ចិត្តជិះកង់ឃ្លើស១ មកពីរកទិញសៀវភៅមើលមួយនៅឯផ្សារហើយជិះកាត់តាមផ្លូវលំមួយក្រោយចំការរបស់គេ ដែលមានទិដ្ឋភាពស្រស់បំព្រងគួរចាប់ចិត្ត ។ ជិះកង់បណ្តើរហួចបណ្តើរ មកដល់គុម្ពោធព្រៃមួយចិត្តនឹកឃើនោមជ្រួច ក៏ទម្លាក់កង់ព្រូស ! ហើយស្ទុះទៅក្បែរគល់ឈើមួយដោះឡេវខោបណ្តើរ ។

ទើបនិងដោះបានឡេវមួយ ស្រាប់តែឮសូរក្រឹក ! នៅក្បែរព្រមទាំងមានសម្លេងភ្ញាក់ដ៏ស្រួយខ្នោកមួយ១ :

-យឺ !... ស្រេច ! ... ជាប់ស្រេច ! ...

ចិត្តអាក់សទ្ធា ក៏បង្វិលក្បាលរ៉ូប៊ីណេទៅបញ្ចេញនៅទីផ្សេងវិញឮសូរឆ ! ... ព្រោះគេដឹងថា នៅក្បែរនោះមានស្រីម្នាក់ទើបនិងស្ទុះចេញមក ។ គេសួរទាំងបែរខ្នង :

-អាស្រី ! ... អាស្រី ! ...មកពីអង្កាល មកធ្វើអ្វីនៅកន្លែងហ្នឹង?

យុវនារីថ្ពាល់ខួច ដែលដៃស្តាំមានកាន់ម៉ាស៊ីនថតផងនោះក៏តប :

-មកដល់ជិតមួយម៉ោងទៅហើយ... អផ្សុកពេកក៏ចូលមកដើរលេងក្នុងចំការបង ចិត្តឯងហ្នឹងណា៎ !

លុះបន្ទោរបង់រួចហើយយុវសិស្សក៏បែរចំមកទាំងញញឹមពព្រាយ

-ស្មានតែពីណា... មិនដឹងជាអាស្រីសោះ មើលមួយភ្លែតស្ទើរតែមិនស្គាល់...ឥឡូវនេះធាត់រាងកំប៉ោង១ ដូចកំពឹងដូង ! ... អុឺ... ចុះស្អីក្រឹកជាប់ស្រេច ! ... អំបាញ់មិុញ ?

យុវនារីតបញ្ជាប់១ ហាក់ដូចជាស្តាយវត្ថុអ្វីម្យ៉ាង :

-ដើរមកដល់ត្រង់នេះ ឃើញមេអំបៅមួយស្អាតប្លែក !... ក៏លបថត... ព្រោះវាទុំលើមែកឈើមួយស្រាប់ ពេលដែលច្របាច់ ស្រាប់តែលេចបងឯងឈ្លើមមក ! ...

-អីចឹង... ក្រឹក ! អំបាញ់មិុញអាស្រីច្របាច់ម៉ាស៊ីនថតទេហ្អី?

-ហ្នឹងហើយ... អ្នកណាទប់ទាន់ បើ... រវល់តែផ្ទៀងមើលមេអំបៅ... ស្រាប់តែបងឯងចេញធ្លោមក ? ...

ចិត្តប្រហោងពោះធ្លុងយកដៃអេះក្បាល :

-គ្រោះជាឯងទើបនឹងដោះបានឡើវមួយ ! កុំអី... ចិនលាងរូបសុំខ្មាស់ ។ ចិត្តយកដៃអេះក្បាលបន្តិច ទើបសួរទៀត :

-លោកមា លោកមីងគាត់អញ្ជើញមកទាំងអស់គ្នាឬ ?

-អត់ទេ មកតែប៉ា ! ... គាត់កំពុងតែជាប់មាត់ជជែកជាមួយប៉ាបងចិត្តណា៎ !

-ម៉ោហ៏ ! ... ទៅផ្ទះវិញប្រយ័ត្នគាត់រក...ទំខាងក្រោយកង់នេះមក !

-ទេ ! ...ដើរបានហើយ !

អាងតែផ្ទះនៅជិត ចិត្តក៏មិនបង្ខំអីទើបធាក់កង់មកមុន ឯកញ្ញា (អាស្រី) ក៏ដើរលេងមកតាមក្រោយ ។ ចិត្តមកដល់ផ្ទះក៏បានជួបនិងលោកសំណាង ដែលត្រូវជាឪពុកមាគេបង្កើត (គឺប្អូនខាងម្តាយ) កំពុងសាសងសើចលេងជាមួយគ្រួសារគេយ៉ាងរីករាយ ។

ក្រោយពីឃើញយុវជនភ្អែកប្អូននេះ សម្តែងការគោរពទៅកាន់ខ្លួនរួចហើយ លោកសំណាងក៏ឧទានថា :

-អុឺ...ក្មួយចិត្ត ប្រហែលជាខំរៀនណាស់ហើយបានជារហ័សអន់ភ្អែក រហូតដល់ប្រើវ៉ែនតា តាំងពីនៅក្មេង...

ចិត្តកម្រើកបបូរមាត់រៀបនិងឆ្លើយ ស្រាប់តែឪពុកគេឆ្លើយកាត់

-មើលទៅ កូនហ្នឹងដុះគ្រាន់បើ... តែទាស់ពេលវ៉ាកងអីវាមិនព្រមទៅរៀន (គួរ) និងគេសោះ... មិនដឹងវាយល់យ៉ាងណា...

-ចិត្តគេយល់ត្រូវហើយបងបានជាមិនរៀន ! ម្យ៉ាងទៀត ប្រហែលជាគេពូកែគ្រប់គ្រាន់ហើយអ្វី ... បើអាស្រីរៀនឯសាលាផងរៀនគួរផងខ្ញុំជួយឆ្អើសឆ្អៀលទៀតក៏នៅតែដាច់ឆ្នាំម្តងៗ ជាប់ទាំងលំបាក !

ពូសុខញញឹម កាលបើឮប្អូនសរសើរកូនប្រុស តែជូនពេលនោះចិត្តក៏បន្លឺភ្លាម :

-លោកអឺសរសើរខ្ញុំខុសបន្តិចហើយ ការពិតខ្ញុំមិនរៀនពូកែណាស់ណាទេ គឺគ្រាន់តែទប់ទល់បានទៅមុខគ្រឹតៗ យឺតៗ ដូចរទេះដឹកស្បៀងប៉ុណ្ណោះ តែដែលខ្ញុំមិនរៀនគួរព្រោះលោកគ្រូខ្ញុំម្នាក់បានប្រាប់ថាការដែលក្រសួងសិក្សាធិការកំណត់ពេលម៉ោង ឱ្យរៀននោះគ្រប់គ្រាន់ណាស់ទៅហើយ ឱ្យតែសិស្សម្នាក់ៗយកចិត្តទុកដាក់កុំរវើរវាយ ។ ចំណែកពេលវ៉ាកងបានជាគេឱ្យឈប់ ព្រោះគេយល់ពេលហ្នឹងវាក្តៅពេក ឬត្រជាក់ពេកធ្វើឱ្យសិស្សរៀនមិនកើត... ទើបគេសម្រេចឱ្យមានការលំហែ តែសិស្សខ្លះបែរជា (ជោរ) រំអុកឪពុកម្តាយទៅសុំរៀនគួរទៅវិញ !

ពូសុខឆ្លើយកាត់ :

-កាលណាគេរៀន (គួរ) តែអាចចេះច្រើនជាងសិស្សដែលមិនរៀនអីចឹងដែរណា៎... ហើយថែមទាំងបានលេខល្អនៅក្នុងថ្នាក់ទៀតផង ។ ចិត្តយល់ថា ពូសុខមានយោបល់មិនស្របនិងខ្លួន ប៉ុន្តែក្នុងចរិតជាកូនថ្លៃថ្នូរគេមិនហានតមាត់ជជែកប្រឆាំងចំពោះគាត់ឡើយ ។ កណ្តាលបរិយាកាសស្ងប់ស្ងាត់នោះលោកសំណោងក៏ឧទានវិញ :

-ត្រូវហើយ ! ត្រូវហើយក្មួយចិត្ត ! ព្រោះភាគច្រើនដែលពូសង្កេតទៅ ឃើញសិស្សខ្លះដែលទៅរៀនគួរ ច្រើនតែមិនសូវមានប្រសិទ្ធិភាពប៉ុន្មានឡើយ...ខ្លះទៅរៀនឱ្យតែបាត់ៗ ជៀសវាងកុំឱ្យឪពុកម្តាយ ប្រើឱ្យធ្វើការនៅផ្ទះ ខ្លះមានអធ្យាស្រ័យមិនល្អ ក៏ទៅដើរលេងហ៊ឺហារច្រើនជាងរៀន... គិតឱ្យសព្វៗទៅ ហាក់ដូចជាយកលុយឪពុកម្តាយទៅបង្ហិនស្មោះ...
ព្រោះថា ឱ្យតែយកចិត្តទុកដាក់គ្រប់ពេលម៉ោងដែលរៀនមែនទែននោះ វាគ្រប់គ្រាន់ណាស់ទៅហើយ ! ...

ពូសុកដកដង្ហើមធំៗ ទើបសម្លឹងមើលមុខចិត្ត :

-អ៊ើ ! ... បងយល់ថា ... បើយើងពូកែស្រាប់ហើយរៀនបន្ថែមទៀតហ្នោះ វាកាន់តែឆ្អិនមែនទែនណា៎ មិនបាច់បារម្ភអ្វីទេដល់ពេលប្រឡង !

ការសន្ទនាចេះតែដំណើរត្រិបៗទៅមុខទៀត ។ ម្តងនេះស្រាប់តែចិត្តបន្លឺថា :

-តែឆ្នាំនេះ ខ្ញុំដូចជាចង់សុំរៀន (គួរ) ! ...

អាស្រី...ដែលអង្គុយជិតនោះបើកភ្នែកធំៗ ចោលរស្មីភ្នែកដ៏ស្រទន់មករកយុវជនភ្នែកបួន ឯពូសុខក៏លាន់មាត់ :

-អ៊ឺ... ក្រែងឯងរិះគន់អ្នករៀន(គួរ) អ្ហ៎... ឥឡូវម៉េចក៏ចង់រៀនទៅវិញ... ឯងភ័យខ្លាចធ្លាក់ឬ ?

ចិត្តអិមអៀនបន្តិច ទើបពោលដោយលួចចោលកន្ទុយភ្នែកទៅប្អូនជីដូនមួយបណ្តើរ :

-មិនភ័យទេប៉ា ! ...ប៉ុន្តែចង់បានពិន្ទុល្អពីមណ្ឌលប្រឡង ...ហើយដូចជាចង់សាកល្បងតាមពាក្យប៉ាម្តងទៅចុះ តើរៀនគួរនោះវាបានចំណេញដូចលោកប៉ាយល់មែនឬយ៉ាងណា ?

ពូសំណាងជាមនុស្សហៃអើ កាលបើឮចិត្តថារៀនគួរ ក៏ចាក់បណ្តោយបែបនេះវិញ :

-អ៊ឺ... បើក្មួយរៀនក៏ប្រសើរដែរ... ប៉ុន្តែនៅទីនេះមានបង្រៀនសម្រាប់ពេលវ៉ាកងដែរឬ ? ...

-បាទ ! អត់មានទេលោកពូ ! ... ខ្ញុំកំពុងតែគិតថានិងសុំប៉ាទៅរៀននៅភ្នំពេញក្នុងពេលវ៉ាកងនេះ !

-យី!...ក្មួយឯងមានគំនិតល្អណាស់!... ទៅរៀនភ្នំពេញហើយសំណាក់នៅផ្ទះពូទៅមានជាទាស់ខុសអ្វី... ព្រោះសព្វថ្ងៃថាអន់ចំណោទណាស់ !... ម្យ៉ាងទៀតពូចង់ឱ្យវាមានឈ្មោះបោះសំឡេងខ្លះ នៅពេលប្រឡងចូលថ្នាក់ទី ៦ នោះ !

នៅពេលដែលការសន្ទនា សសៀរមកដល់ត្រង់នេះ ម្តាយចិត្តក៏ត្រឡប់មកពីផ្សារល្ងមហើយយល់ថាកូនប្រុសចង់ទៅរៀនភ្នំពេញក៏យល់ព្រម :

-អ៊ឺ... បើវាសុខចិត្តទៅរៀនគួរនិងនៅភ្នំពេញ ឱ្យវាទៅសំណាក់ផ្ទះសំណាងឯងចុះ ហើយជួយមើលការខុសត្រូវស្តីប្រដៅវាផងណ៎ា !

ពូសំណាងញញឹមដាក់បងស្រី :

-មិនអីទេបង... កូនក្មួយខ្ញុំមិនបណ្តែតបណ្តោយទេ ! ...

... ដោយបានទទួលការស្រុះស្រួលពីឪពុកម្តាយយ៉ាងនោះហើយនិងដល់ថ្ងៃស្អែកដល់ពេលវិស្សមកាលតូចជាងនោះ ចិត្តក៏ចាំបាច់ត្រូវរៀបចំខ្លួនធ្វើដំណើរជាមួយលោកពូសំណាងមកភ្នំពេញភ្លាម ។

លោកសំណាងជាភ្នាក់ងាររដ្ឋការថ្នាក់មធ្យមម្នាក់ មានកេរ្តិ៍ឈ្មោះស្អាតស្អំ ធ្វើការនៅក្រសួងកសិកម្មមានកូនប្រាំក្នុងបន្ទុក និងមានទីស្ថានផ្ទះសម្បែងនៅច្បារអំពៅ ។(អាស្រី) កូនច្បងរបស់គាត់កំពុងរៀននៅថ្នាក់ទី ៧ នៃសាលាបឋមសិក្សាប៉ុណ្ណោះ ប៉ុន្តែមានអាយុ ១៥ឆ្នាំ ទៅហើយ ។

វ័យរបស់អាស្រី គឺជាវ័យដែលបុប្ផជាតិកំពុងរីកក្រពុំ ជាទីប្រជុំឆក់ទាញអារម្មណ៍ភូមរាឱ្យប្រាថ្នាក្រេបលំអង ។

តាមការពិត ! ... ក្នុងវ័យនេះអាស្រីមានរូបសម្ផស្សណែនក្តន់គួរចាប់ចិត្ត មានទម្រង់មូលដូចដួងខែក្នុងមេឃគ្មានពពក ដែលចាត់ទុកថាជាវ័យដែលឈានចូល ( លៃរៀនស្នេហា ) ។ ប៉ុន្តែបើពិនិត្យឱ្យច្បាស់ អាស្រីមិនដែលនឹកនាដល់រឿងស្នេហាសូម្បីតិចតួចឡើយ ។ នាងសើចនាងញញឹម នាងនិយាយ ទាំងប៉ុន្មានគឺសុទ្ធតែក្នុងន័យបរិសុទ្ធដែលចេញពីក្រអៅបេះដូងពិតៗ ទោះបីសំដីខ្លះដែលនាងនិយាយហើយត្រូវយុវជនខ្លះយកទៅវែកញែកថាជាសំដី ( ស្នេហា) ក៏នាងឥតដឹងខ្លួនជាមុនដែរ ។

~២~

## គ្រូភ្នែកបួន និងសិស្សបួសខ្លួន

**គ្រូ** ចិត្តបង្ហាត់មិនយកលុយ
**ខិល** មិនទុយមុយរុយរោមមាត់
**សិស្ស** ឆ្លាតរវៀសមេរៀនស្ទាត់
**ខូច** ត្រឹមតែមាត់អត់បានការ ។

**រាល់ល្ងាច...** លោកសំណាងដោយអាងថាអាគកមកពីស្រែនិងជាប់សែជាប់ស្រឡាយមិនឆ្ងាយប៉ុន្មានផង ក៏ផ្តល់ការគ្រប់គ្រងទាំងស្រុងឱ្យទៅនាយចិត្តក្ដួយគាត់ ក្នុងនាមជាគ្រូបង្ហាត់បង្រៀនវិញ្ញាសារខ្លះដល់កញ្ញា... អាស្រីដែលនាងជិតដល់ថ្ងៃដល់ខែប្រឡងចូលកូឡែសហើយនោះ ។

លោកគ្រូចិត្តឆ្លៀតបន្ថែមម៉ោងដោយឥតគិតថ្លៃ ពេលកំបាំងពីភ្នែកអ្នកស្រីចំណាប់ឬលោកសំណាង... ដើម្បីបង្រៀនវិញ្ញាសារស្នេហានិងចម្រៀងខ្លះៗ ។ ល្ងាចនេះកំម្លោះចិត្តកំប្លែងបន្ទិចថា :

-រថយន្តមួយធ្វើដំណើរពីច្បារអំពៅទៅផ្សារ ខេត្តកំពងចាម ឆ្លងតាមទន្លេមេគង្គ ក្នុងឡាននោះមានផ្ទុកមនុស្សពីរនាក់...

គេអាក់បន្ទិចលើដៃឡើងប្រាប់នាងក្រមុំថា :

-នៃប្រយ័ត្នបន្ទិចណា៎ ចំណោទនេះពិបាកណា៎ ប្រយ័ត្នធ្លាក់ តែប្រឡងចំអាចំណោទធុនហ្នឹងប្រឹងឱ្យហើយទៅ...

នាងមិនឆ្លើយតបទេ គ្រាន់ងក់ក្បាលឮអឺបន្ទិចតែបែបទ្រង់ឆ្ងល់ ។ លោកគ្រូក្មេងក៏បន្តទៅទៀត :

-ចម្ងាយពីផ្សារអំពៅទៅផ្ទះវមានប្រវែងអឺ... ៧០គីឡូម៉ែត្រ...

សួរថាតើស្រី និងប្រុសនោះទៅដល់នៅម៉ោងប៉ុន្មាន ហើយទឹកទន្លេមេគង្គមានប៉ុន្មានម៉ែត្រ ?

-ទេស ! មិនដឹងជាចំណោទស្អីអញ្ចឹងទេ ! ពេលនោះសម្លេងអ្នកស្រីជាម្តាយមាណវីឮពីក្នុងបន្ទប់គាត់មក...

វើយកុំដុតម៉ាំងសុងបង្ហិនប្រេងវ៉ី វេ្យន១ កុំអាល័យតែលេងសើចច្រើនពេក ! ...

ចិត្តតបទាំងលាយសំណើចខ្លះទៅម្តាយមីង :

-នៅសាលាក៏មានពេលចេញលេងដែរមីង នេះទុកដូចជាពេលចេញលេងអញ្ចឹងទៅចុះ !

គាត់បែបបន្ទូរចិត្តមកវិញ :

-អើ ! កុំនិយាយអាពាក្យមិនបានការ នាំខាតវេលាខាតប្រយោជន៍ណា៎ ។

គ្រានេះ កូនសិស្សស្រីលូកមាត់ស្តីឱ្យត្រូកម្លោះ :

-ឃើញទេចិត្តឯង នាំលេងច្រើនម៉េចម៉ាក់ស្តីឱ្យស្រួលទេ ?

-យើងទាំងពីរនាក់ ស្ថិតនៅក្នុងព្រៃរហោស្ថានពេលណាគាត់នៅនឹងមុខ រួចពេលដែលគាត់រវល់ទៅប្រឡែងគ្នានេះ តាមការស្មានទេណា៎...

-ប្រាប់ម៉ាក់ឥឡូវហើយ !

-កុំមាត់...យើងទាំងពីរនាក់ ក៏ស្ថិតនៅក្នុងខ្សែភាពយន្តមួយវគ្គដែរ មិនថាអញ្ចឹង !

-មិនដឹងទេ !

-ឥឡូវនេះដឹងទៅចុះណា៎ សព្វថ្ងៃនេះបន់ឱ្យតែយប់ទេ...

-បន់ឱ្យតែយប់និងអាលធ្វើអ្វី ? ហ៎ចិត្ត ! នាងសួរបែបឆ្ងល់ ។ កំលោះបរិសុទ្ធដើមទ្រូងប្រាំហត្ថពីរធឹង ឆ្លើយសម្លឹងទៅវិញថា :

-ឱ្យយប់និងអាល់បានបង្រៀនអាស្រី បាននិយាយលេងបានស្តាប់សំម្លេង...

-នែ៎ កុំណា៎ !

- - - - - - - - - - - - - - - - - - - - - - - -

បុប្ផាក្រពុំ រីករហង់នៅបបូរមាត់បន្ថែមសម្ផស្សឱ្យធីតានេះស្រស់ឥតពីរ បង្ហក់ស្មារតីនាយចិត្តឱ្យឆ្អែតចិត្តឥតនិយាយចេញ ។

តែបើពេលនេះយើងចេះស្តាប់ភាសាបេះដូង យើងប្រហែលជាបានឮថា បេះដូងគេសារភាពថាស្រស់ ថាល្អ ថាគួរស្រលាញ់ណាស់ថ្វីត្បិតតែគេត្រូវជាបងប្អូនជីដូនមួយបង្កើតនិងគ្នាក៏ដោយ...

តាំងពីថ្ងៃដែលគេពេញរូបពេញរាងរហូតមក បានជួបអាស្រីបុរស ចិត្តក៏ចាប់ចិត្តាតាងស្និតលួចប្រតិព័ទ្ធនោមនារី...

ប៉ុន្តែចោរនេះជាចោរលួចឱ្យគេដឹង !

ល្ងាចមួយទៀត...

-សរសេរតាមសូត្រ ( ថាឮៗ)

ពាក្យចាស់លោកពោលថា បុរសតែងស្រឡាញ់ស្រីៗណាដែលនៅជិតខ្លួន ( ថាតិចៗទៅវិញ) រួចបន្ថែមទៀតថា :

-តែងណេះ អត់ស្រឡាញ់អាស្រីឯងទេណា៎ គ្រាន់តែ...

-គ្រាន់តែស្អី ? ( នាងគំហកឱ្យ)

-គ្រាន់តែ...អត់ដឹងគ្រាន់តែស្អីផង ! ( សើច) នាងឱនមើលទៅក្រោយតុ...

-អ៊ូ៎ គ្រាន់តែយកជើងដ៏សែនខូចដូចស្វាប៉ាហ៊ីលូកកេះជើងគេម្ដងៗអញ្ចឹងហ៎ ?

កំលោះញញឹមតប :

-អាហ្នឹងបញ្ជាក់ឱ្យដឹងថា បេះដូងឯណេះវាសម្រូតដល់ចុងជើងទៅហើយ !

-ណ្ហើយអ្នកនិពន្ធហួសសម័យអើយ ប៉ុណ្ណឹងបានហើយ !

គេទាំងពីរនាក់តែងនិយាយរកគ្នាចំឈ្មោះ តែបើបែរឆ្ពោះមករកខ្លួនគេម្នាក់ៗវិញ គេតែងថាអីណុះ គេដូចជាមិនព្រមបញ្ចេញសោះនូវពាក្យថាខ្ញុំ ហើយប៉ែកខាងនាងក្រមុំ នាងច្រើនប្រើពាក្យបារាំងថាMOIឬចង្អុរដើមទ្រូងនាង ជំនួសពាក្យថា ចាំ ដែលវាកប់ដល់ក្រហែងណាមិនព្រមចេញ ។

ទាំងនេះមកពីហេតុអីទៅ ?

គេទាំងពីរនាក់ជាបងប្អូននឹងគ្នាមែន តែដូចជាពុទ្ធសែនមិនដែលជួបកម្រើអញ្ចឹងដែរ ។

លុះដល់ពេលគេមករស់នៅក្បែរ ហើយភ្លើងស្នេហ៍ឆាបឆេះ ។ ឱ្យគេហៅគ្នាថាប្អូនបងដូចជាវាល្អកល្អឺនពេក ឱ្យគេហៅថា អាម៉ឹងមីនេះមីនោះ ដូចជាមិនសម ព្រោះម្នាក់ៗ សុទ្ធតែជាកូនមានពូជជាពិសេសដូនតាតែមួយ ។

បើអញ្ចឹងទុកឱ្យគេចង្អុលដើមទ្រូង និយាយដាក់គ្នារហូតអញ្ចឹងទៅចុះ ។

ម្ដងៗដែរកម្លោះប្រស់ហត្ថា មកបន្ទំប៉ះដៃក្រមុំដែលលំអដោយក្រចកស្រួចទាំងដប់អប់ដោយក្លែបក្លិនគួរឱ្យប្រតិព័ទ្ធ ។

ភ្នែកទាំងបួនតែងទម្លាក់ចុះជានិច្ច ពេលណាក្រសែវាទង្គិចប៉ះគ្នា នាពេលគេខ្មាញ់សម្លឹងមុខដោយកើតទុក្ខមិនសុខចិត្តរឿងស្អីមួយ ។

ម្ដងនេះ...

-មូសៗ ! (កម្លោះទះស្រាលលើកំភួនដៃស្រី នាងសម្លឹងថ្លៃ) ។

-គ្មានភស្តុតាងទេណា៎ កុំខូចពេក ឯណាមូស

-វាហើរបាត់ទៅហើយ !

-ចិត្តឯងឱ្យល្មមៗបានហើយ ។

យុវបុរសលើកដៃឡើងលើ :

-ឱលោកម្ចាស់អើយ ! សូមមូសខាំអាស្រីឱ្យច្រើនមកលោក !

- គេមានដៃទះហើយ មិនបាច់មក...។ គ្រានោះលោកសំណាង ដែលជិតសម្រាន្តលក់ទៅហើយ ឆ្លើយពីក្នុងបន្ទប់មក :

-ស្អីនៅមានមូសខាំទៀតហ៎ ? អាចិត្តហា៎ ឯងមើលយកATOX ក្រោមទូយកទៅបាញ់ថែមទៀតទៅ ! មូសស្រុកនេះធំៗ ណាស់វើយ...

-បាទពូមូសស្រុកច្បារអំពៅហ្នឹងខ្ញុំដឹងហើយ គេហៅថាមូសដែក ខ្នង ។

នាងស្រីនិយាយតិចៗខ្លាចឪពុកឮ :

-គ្មានមូសផងយកថ្នាំមកបាញ់ធ្វើអ្វីប៉ាអើយ នាំឱ្យតែអស់លោក គ្រូនេះខូចទេ !

-កុំមាត់កូនសិស្ស តិចឱ្យ ZERO ឥឡូវ !

-ហ៊ឺឱ្យ ZERO ផង !

- - - - - - - - - - - - - - - - - - - - - - - -

ល្ងាចនេះលោកសំណាង ក៏ចូលរួមតុវែងជាមួយគ្រូសិស្សទាំងពីរ នេះដែរ :

-អាចិត្ត, អាស្រីវាល្ងង់ណាស់ មើលបង្ហាត់ប្អូនឱ្យស្រួលអ្នែង និយាយមួយៗមើលកុំឱ្យញាប់ពេក ។ អ្នែងនិយាយមើលតែទឹកធ្លាយទំនប់ អញ្ចឹងនរណាស្ដាប់បាន ! ។

-ធ្វើម៉េចបើទម្លាប់ខ្ញុំអញ្ចឹងទៅហើយពូ !

-អ៊ើរៀននិយាយរង្វើលទៅ ដល់ទៅធ្វើគ្រូគេឱ្យគេស្ដាប់បានខ្លះ ផង ។

លោកបែរទៅមើលមុខកូនស្រី ដែលកំពុងសរសេរ

-សរសេរស្អីហ្នឹងអាស្រី !

-ចាំស EXERCICE ប៉ា !

-អាចិត្តអាំ ! អាស្រីវាអន់បារាំងណាស់ មើលឧស្សាហ៍ប្រាប់ប្អូនបន្តិចណាំ

-បាទពូ !

-មើលឆ្នាំហ្នឹងប្រឡងកុំឱ្យធ្លាក់បានទេ ? គាត់ងាកទៅសួរកូនស្រីសម្លាញ់ តែនាងមិនឆ្លើយ នាយចិត្តក៏ឆ្លើយជំនួសថា :

-បើច្រៀងអត់ភ្លេងដូចគ្នាវិញនោះ ទោះនាងរស់សីរីសុទ្ធាដែលគេគ្រប់គ្នាថាល្បី ក៏ស៊ីមិនដាច់អាស្រីដែរពូ !

នាងលែងសរសេរ សម្លឹងខ្ទាញ់ផុតលេខហើយស្រែកថា :

-ចេះតែថាហើយ ! ...

លោកសំណាងលាន់មាត់ :

-ចេះតែថាអីវាអញ្ចឹងមែន ! អញឃើញវល់តែកត់ច្រៀងសោះសៀវភៅមួយ៉ៗ

ពេលជាមួយគ្នានោះ អ្នកស្រីចំណាប់ក៏ស្រែកប្រាប់មកប្តីពីបន្ទប់ម្ខាងថា :

-នែ៎ ប៉ាវ៉ា មកមើលអាដាម៉េចក៏ក្តៅខ្លួនខ្លាំងម្ល៉េះ ?

ឮដូចច្នោះអាដ្ឋាកណ្តាលនៃគ្រូភ្នែកបួន និងកញ្ញាច្បារអំពៅក៏ចាកចេញពីតុវែងទុកឱ្យគេទាំងពីរនៅសម្លក់សម្លឹងគ្នាតទៅទៀត ។

អាស្រីចាប់ផ្តើមភ្លាមដោយខ្ទាញ់ខឹង :

-ចិត្តឯងនេះអស្ចារ្យតែម្រ៉ង ធ្វើឱ្យប៉ាស្តីឱ្យគេ ចាំមើលណាំ ...

-ចុះបើសារិកាកែវវងក៏មិនដល់សម្លេងអាស្រីឯងដែរ តើឱ្យថាម៉េចទៅវិញ ?

-ម៉េចចាំបាច់និយាយឱ្យប៉ាឮ ចាំពេលស្ងាត់សរសើរមិនបានឬ ?

ចិត្តបើកភ្នែកក្រឡង់ដូចជីងចក់រលូត :

-អីចឹងសុំសរសើរនៅពេលហ្នឹងបានទេ ?

-ណ្ហើយ !បានហើយខ្ជិលឱ្យសរសើរណាស់ ! ...

~៣~

## ដឹងចិត្តគ្នាហើយ

**សូម** ស្រស់ជីវ៉ាមេត្តាបង

**ស្គាល់** ចិត្តថ្លើមផងកុំកាចពេក

**រស** ស្នេហ៍ថ្កាល់អូនប្អែមដូចចេក

**ជាតិ** ជាពស់វែកគង់មានពិស ។

...ព្រឹកមិញមានជនម្នាក់បានមកប្រាប់ថា លោកតាប្រាក់ដែលត្រូវជាឪពុករបស់លោកសំណាង ហើយដែលសព្វថ្ងៃសំណាក់នៅជាមួយម្ដាយចិត្តឯស្តន់នោះ ចាប់ផ្ដើមមានជំងឺជាទម្ងន់... ។

ចិត្តនិងអាស្រីគ្រាន់តែឮដូច្នេះ ក៏មានចិត្តរំភើបពន់ប្រមាណព្រោះតាប្រាក់ក៏ជាជីតារួមរបស់គេដែរ គេមានទឹកមុខស្រពាប់ស្រពោនភ្លាមរុញច្រានបរិយាកាសក្នុងផ្ទះឱ្យធ្លាក់ចុះទៅក្នុងសេចក្ដីតប់ប្រមល់មួយដ៏ខ្លាំងក្លា

លោកសំណាង បានដាក់បញ្ជាឱ្យអ្នកស្រីចំណាប់ចេញដំណើរមកមើលថែជម្ងឺឪពុកនៅវេលាស្អែក ចំណែកគាត់និងចេញដំណើរទៅតាមក្រោយកាលណាសុំច្បាប់បានហើយ ។

...រាត្រីនេះបរិយាកាសដូចជាស្អុះស្អាប់ប្លែក ពពកនាំគ្នារសាត់ទៅជ្រកនៅជើងមេឃ ។ ផ្កាយគ្មានរះ ស្លឹកឈើគ្មានកំម្រើក... ក្លិនផ្កាស្ងួនលែងក្រអូប ។ ម្នាក់ៗចាំដកតែដង្ហើម ហើយគ្រវីក្បាលញយៗហាក់ដូចធុញទ្រាន់និងរឿងអ្វីម្យ៉ាង ។

នៅបន្ទប់ខាងក្នុង អ្នកស្រីចំណាប់កំពុងរៀបចំប្រដាប់ប្រដារដើម្បីនាំកូនក្មេងខ្លះទៅមុននៅវេលាស្អែក ។

ម៉ោងជាងប្រាំបីហើយ...

កម្លោះសែនឆ្អែតចិត្ត ទើបនិងប្រាស់ខ្នងទៅលើក្ដារឿយ៉ាងរលោងមួយដែលគេចាត់ទុកថា ជាទេនស័យនាដ៏ត្រកាលសម្រាប់ខ្នងគេតាំងពីពេលដែលគេបានមកជ្រកកោននិងផ្ទះឪពុកមា ក្នុងពេលវិស្សមកាលនេះ ។

ខណៈដែលអារម្មណ៏គេ ចាប់ផ្ដើមហើរព្រោងព្រាយដូចកំស្ទួលផ្សែងបារី ស្រាប់តែនៅប្របមាត់បង្អួច មិនឆ្ងាយប៉ុន្មានពីខ្លួនគេ ស្រមោលនាងតូចស្ដើងរបស់អាស្រីក៏បានមកប្រាកដនៅទីនោះ ។

ចម្រៀងមួយបទដែលគេធ្លាប់ឮនាង រស់-សេរីសុទ្ធា ច្រៀងក្នុងខ្សែភាពយន្ត (ស្អែកអូនលាបងហើយ) ក៏ឮសាយភាយល្ហិមៗ ចេញពីបបូរមាត់ដូចផ្កាឈូករបស់អាស្រីធ្វើឱ្យគេព្រឺក្បាលសំពោង :

-ថ្ងៃស្អែកថ្ងៃថ្មី ថ្ងៃស្រីព្រាត់ទៅ

យប់នេះអូននៅរួមរស់ក្បែរបង...

មិនចាំតែចិត្តដែលធ្វើឪគេបាននោះទេ ទុកណាជាក្មេងដែលទើបនិងកាត់ទងផ្ចិតហើយក៏អាចដឹងដែរថា ដែលអាស្រីច្រៀងបទនេះ គឺច្បាស់ជាផ្ញើសផ្ដងចង់ប្រាប់ឱ្យកម្លោះមីញ៉ូបដឹងថា (ស្អែកនេះ នាងទៅមើលជម្ងឺជីតាដែរ) ។

លោកគ្រូកម្លោះ បង្អើបក្បាលពីក្ដារង្វើយឺតៗ សម្លឹងមើលទេពធីតាច្បារអំពៅ ដែលគេធ្លាប់ឱ្យរហ័ស្សនាមថាជា (សំបូរមាស ទងដែក) ដោយទឹកចិត្តរំភើបពេក ។

បេះដូងនិងខួរក្បាលគេដូចជាពើតប៉ោងរីករួញទៅតាមចង្វាក់បទដែលមាណវីច្រៀង ដែលមានសំនៀងដូចសៀងសត្វករវីកក្នុងព្រៃមន្ដទិព្វ ។

ស្នេកអូនលាបងហើយ !

មិនមែនជាបទដែលគេធ្លាប់ច្រៀងក្នុងកុននោះទេ ថ្វីត្បិតតែទំនុកដូចក៏ដោយ ។

បទនេះ ប្រាកដជាលេចចេញពីក្រហែងបេះដូងមួយដែលឆ្លើយស្រេចទៅហើយថាស្ម័គ្រ ព្រោះន័យបទនេះវាស្របទៅតាមសាច់រឿងទាំងស្រុង ។

ពាក្យអូនឬពាក្យបង គេមិនដែលប្រើដាក់គ្នាទេ ព្រោះមិនដឹងជាមានអ្វីមកខ្ទាស់បំពង់កមិនឱ្យបរិយាយពាក្យដ៏ពិរោះកើត ប្រហែលជាវាល្អកល្អនពេកក៏មិនដឹង ។

ប៉ុន្ដែអ្នកទាំងពីរបែរជាប្រើពាក្យដដែលនេះក្នុងចម្រៀងដោយចៀសវាងនូវសេចក្ដីខ្ទាស់អៀនក្នុងរឿងស្ម័គ្រ ! ។

ទ្រាំមិនបានចិត្តក៏ងាកទៅសួរ នៅពេលដែលចម្រៀងទន់ចុះ :

-អាស្រីហាំស្នេកនរណាទៅមើលតាឈឺខ្លះ ?

-ម៉ាក់, អាដា, អាដួង និងសារុំធ...

-ចុះអាស្រីឯង ?

-ទៅដែរ !

-ហ៊ឺ ! ចង់ទៅដែរប៉ុន្ដែ...!

-អ្នកកម្លោះគេងសណ្ដូកតាមប្រវែងក្ដារង្វើ ឯអាស្រីក៏ដើរមកអង្គុយតែមក្ដារង្វើ ត្រឹមត្រង់ណោះមនុស្សដោយសុភាព ។ ម្ដងនេះនាងមិនច្រៀងទេ នាងគ្រហឹម ។ប៉ុន្ដែខ្យល់សម្លេងដែលចេញមកនោះក៏នៅតែជាបទស្នេកអូនលាបងហើយដដែល ។ កម្លោះពេញកម្លាំងបន្លឺថា :

-នៅសាលាគេបងជាវាគ្មិនម្នាក់ដែរ តែដល់មកជិតអាស្រីវាចេះតែល្មិចទេនិយាយស្ដីអីដូចជា...

អាស្រីទឹកឆ្ងល់ :

-ដូចជាយ៉ាងម៉េច ?

ចិត្តនៅស្ងៀមមិនឆ្លើយ បណ្ដោយឱ្យបរិយាកាសស្ងាត់ប្រទាញទៅយ៉ាងយូរ ។ ...

ស្ងាត់ហើយស្ងប់ល្អណាស់យប់នេះ...

ព្រះច័ន្ទរះក្រឡង់ចោលរស្មីតូចៗ ទៅក្នុងម្លប់ដើមស្វាយតាមចន្លោះស្លឹក...

ចិត្ត, បុរសខិលលូកដៃមិនសួរខ្ញិលចាប់កដៃអាស្រីជាប់ ។ ដៃនៅក្នុងដៃភ្នែកនៅក្នុងភ្នែក ឯបទចម្រៀងថ្ងៃស្អែកកុំថាត្រឹមច្រៀង សូម្បីតែគ្រហឹមក៏មិនសូវឮផង ។

គេទាំងពីរនាក់ស្ថិតក្នុងភាពវង្វេងស៊ុងមួយរយៈ ។ ដោយខ្លាចខ្មាស់ធម្មជាតិ ព្រោះតែរឿងស្ងាត់នេះ ទើបនារីបង្ហួរវាចារ :

-លែងបានបានគេសម្ងំ ! ចេះតែ...

-មើលលែងដៃទៅ !

លោកគ្រូគ្មានប្រាក់ខែ និងពេញស្នេហ៍សិស្សក្រមុំក៏ផ្ដុំបទចម្រៀងមួយដែលរើសបានមកពីភាពយន្ត រឿងបាត់អូនម្ដេចបាន ?

គឺបទខ្យល់កំពូលភ្នំមកបន្លឺតិចៗ ព្រោះខ្លាចឮដល់ត្រចៀកពូរបស់គេ ដែលគាត់កំពុងជជែកគ្នា ឯបន្ទប់ទទួលភ្ញៀវ :

-ឱ ! វាយោកំពូលភ្នំអើយ ខ្ញុំមិនស្មានឡើយថាអ្នកប្រណី?

មាណវីរូបស្រស់ក៏បោះសំម្លេងក្រអៅក្រអួនតប :

-អូនដឹងចិត្តដោយឥតសង្ស័យ មិនបាច់ថ្លៃផ្ដោះផ្ដងឱ្យស្រីទៀតទេ !

ម្ដងនេះស្ងាត់ដូចចោរលួចមេសេះ...

អត់ឮនរណាបន្តបទចម្រៀងនេះតទៅទៀតសោះ ។

ក្រមុំប្រិមប្រិយក៏សួរភ្លាម :

-ម៉ិចក៏ចិត្តឯងមិនច្រៀងតទៅទៀត ?

-តែប៉ុណ្ណោះវាគ្រប់គ្រាន់ទៅហើយ !

-គ្រប់គ្រាន់ស្អី នែ៎កុំច្រឡំណា៎ MOI ច្រៀងតាមចម្រៀងទេ...

-តែប៉ុណ្ណេះឆ្អែតចិត្តហើយ !

ស្រីស្រស់នឹកអៀន មុខឡើងក្រហមដូចក្រដាសធូប ។ ចិត្តគិតមួយសន្ទុះក៏នឹកឃើញរឿងមួយ :

-អាស្រីហា៎ ?

មាណវីងាកភ្នែក ទាំងផែនភ័ក្ត្រនៅតែក្រហមដដែល :

-ម៉េច...មានការអី ?

ឮសួរបែបកំបុតដូចច្នេះ ចិត្តក៏ថ្ងូរហ៊ឹស ដូចមនុស្សគ្រុនសន្និ

-ហ៊ឹ... គេដែលមិនមែនជាប់សាច់ញាតិ បែរជាស្រួលទៅវិញដូចជាអាទូចជាដើម គេមានសំណាងណាស់ អាងស្រឡាញ់នរណាក៏បាន ខុសតែរូបឯងដែលកើតមកត្រូវជាបងប្អូនជិតដិតអីចឹង ពិបាកណាស់ !

អាស្រីយល់ន័យឃ្លានេះក៏តប :

-នែ៎ បើកុំតែបងប្អូន ក៏យើងមិនស្គាល់គ្នាដែរ !

ចិត្ត ភ្ញាក់ព្រើតក៏ចាក់បណ្ដោយ :

-អីចឹង យើងក៏អាចស្រឡាញ់គ្នាបានដែរហ្ន៎ ពិតមែនតែបងប្អូនជីដូនមួយ តែគ្មានទំនៀមទំលាប់ឯណាមកហាមឃាត់មិនឱ្យយកគ្នាជាប្ដីប្រពន្ធបានឡើយ !

ឮពាក្យចម្លែកនេះ អាស្រីចង់ខ្យល់ចាប់ភ្លាម ដោយសួរផ្ទួន :

-ស្អី ប្ដីប្រពន្ធ ?

-អុំ... ម៉េចក៏ខើចចិញ្ចើមក្រង៉េវៗ អីចឹង មិនស្គាល់ប្ដីប្រពន្ធនេះឬស្អែកៗធ្វើម៉ែគេបានទៅហើយ នៅមិនស្គាល់ទៀត ! ...

ស្រីតូច សម្ងំគិតបន្ដិចដោយក្របួចបបូរមាត់គួរខ្នាញ់ :

-ណ្ហើយ ចាំបើកវចនានុក្រមមើលសិន តើពាក្យហ្នឹងមានន័យថាម៉េចទៅ ?

-ម៉េចក៏មិនបើកវចនានុក្រមបេះដូងមើល ក្រៅពីវចនានុក្រមហ្នឹងគ្មានទេពាក្យប្រពន្ធប្ដីនេះ... ។

នាងស្រីលួចញញឹមបន្ដិច ហាក់ដូចជាបង្ហាញការកម្រើកថ្កាល់ខួចដ៏ក្រហមព្រឿងលឿងពណ៌រម្យត... ។

កម្លោះមុខស្រស់ក៏បន្ថែម :

-ការរួមរស់នៅជាមួយគ្នាជាប្ដីប្រពន្ធដូចជាមិនដែលខានសោះអារឿងឈ្លោះគ្នា ។ មើលមីងនិងពូស្រឡាញ់ចាក់ទឹកមិនលេចទេក៏គង់ថ្ងៃមុនមីងយំម៉ាសន្ទុះដែរ !

ចិត្តអាក់បន្ដិចបែបដូចជាខំលេបទឹកមាត់ឱ្យមានកម្លាំង

-ចុះយើងប្រែជាឈ្លោះគ្នាវិញ យើងជេរនរណា ដៀលពូជនរណាបើដូនតាម៉ែតែមួយនោះ ។ យើងជឿថា លុះអវសាន្តនៃជីវិតក៏មិនមានប្រេះឆាដែរ !

កញ្ញាមួយម៉ឺនសម្រស់តបវិញ :

-ណ្ហើយចិត្តអើយ ពាក្យអវសាន្តរបស់ប្រុសៗ នោះគ្មានទេក្នុងលោកនេះ !

-តែចង់សួរថា យើងអាចស្រឡាញ់គ្នាជាប្ដីប្រពន្ធបានទេ ?

នាងឆ្លើយទាំងត្រដាបត្រដួសខ្លាចហួសព្រំដែនជាបក្សីលើមែកព្រឹក្សា ដែលមានមេបានិងប្រពៃណីជាច្រវ៉ាក់ :

-យើងស្រឡាញ់ទុកដូចជាបងប្អូនទៅចុះ !

-ចុះចាំបាច់ទុកជាបងប្អូនស្អីទៀត សព្វថ្ងៃមិនមែនបងប្អូនទេហ៎?

-យើងរាប់គ្នាជាបងប្អូនមែនណ៎ា ?

ស្មើនិងពាក្យបែបនេះនាងសើចស្រស់ ដែលកម្លោះអស់កម្លាំងត្រូវតែខ្លាំងលើសដីរសារ... ។

ចិត្តសែនឆ្ងល់សែនច្របល់ចិត្ត ត្បិតមិនយល់សម្ដីនិងកាយវិការក្រមុំស្មាវឈាមរាវនៅឡើយ ។

ក្នុងចិត្តនាង នាងពិតជាស្នេហ៍តិចក្ដីច្រើនក្ដីមិនខានឡើយ ប៉ុន្តែបុរសទាំងឡាយអើយ ! ស្រីភេទឯណាងាយឆ្លើយប្រាប់ប្រុសតាមត្រង់ថា នាង ព ដាក់ជើង រ និង ម ហើយថែមស្ម័គ្រទៀតនោះ ។

ដេកចាំស្រីឆ្លើយថាស្ម័គ្រដូចចាំច័ន្ទធ្លាក់ពី...មេឃា ។

មានតែអ្នកដឹងទេទើបបានដឹងថា អាស្រីក៏ស្រឡាញ់ចិត្តមិនតិចដែរ តើបាននរណាជួយប្រាប់គ្នាទៅអេះ បើកម្លោះនេះមិនយល់សោះនោះ ? ។

មួយអាទិត្យក្រោយមក ! ត្រឡប់ពីស្រុកស្រែមកវិញ ការចម្រើនលូតលាស់នៃត្រួយស្នេហ៍ ស្មើរតែមិនជឿថាវាបែកសាខាដូច្នេះសោះ ។

ទាំងកម្លោះទាំងចិត្តក្រមុំ ត្រជុំត្រជាក់រាក់ទាក់រកគ្នាចំណើមួយម៉ាត់ក៏ចែកគ្នា... ។

ទិវាដ៏សែនស្ងាត់បាត់ពីមុខចាស់ទុំកម្លោះក្រមុំសន្ទនា :

-ពាក្យចាស់លោកពោលថា បើចង់ឱ្យដឹងជំម្រៅទឹកគេត្រូវដកដើមព្រលិត ទោះទឹកជំម្រៅណាក៏គេអាចដឹងបានភ្លាម... !

ស្រីស្រស់បោះវាចារផ្ទាន់ឱ្យ :

-ចុះទឹកសមុទ្រមានដើមព្រលិតដែរ ?

គ្រូក្មេងរែងខ្មាស់ក្រឡាស់បន្ថែមសម្ដីទៅស្រីវិញ :

-ព្រោះតែអញ្ចឹងហើយថា មិនថាត្រឹមទឹកសមុទ្រទេ ដែលគ្មានដើមព្រលិតសម្រាប់ស្ទង់កម្រិតទឹក ក្នុងខ្លួនប្អូនជីដូនមួយក៏គ្មានដើមព្រលិតសម្រាប់ប្រមាណទឹកចិត្តបានដែរ ។

-ឱ ! ព្រះអាទិទេពអើយ !

ឱអនិច្ចាថាមិនទៀងអើយ !

-ណ្ហើយកវី...

-ម៉េចស្រីតូច ?

គេសម្លឹងមុខគ្នាយ៉ាងយូរ... ហាក់ដូចជាប្ដូរបេះដូងរវាងគ្នានិងគ្នាឱ្យម្នាក់ៗខំថែរក្សាទុកតាមទំនុកសម្ដី តាមពាក្យរបស់កវី តាមតន្ត្រី តាមសម្លេងច្រៀង តាមភ្លៀង តាមផ្គរ...

តួកវី ដែលយើងដាក់ឈ្មោះឱ្យអម្បាញ់មិញហើយដែលយើងសូមប្រើពីពេលនេះតទៅ បើកក្តោងសំពៅមាត់កាត់ព្យុះវាសនាយ៉ាងរលៀមសាយ :

អាស្រីដឹងទេថា ផ្កាម៉េចក៏គេចូលចិត្តគាស់វាទៅដាំតែផ្កាតូចៗអញ្ចឹង ? ម៉េចគេមិនគាស់អាធំៗ មានផ្លែផ្កាហើយយកដាំវាបានផលឆាប់រហ័សផងហ៎ក ? ។

-អញ្ចឹងក៏ល្ងង់ដែរ !

-មើលអ្នកចេះឆ្លើយមកមើល !

-ព្រោះអាតូចវាតូចឯអាធំវាធំណា៎ ?

-ហ៊ឺ ! ប៉ុណ្ណឹងទេ ?

-នៅ កុំអាល គេឆ្លើយមិនអស់កុំអាលថា :

-ផ្កាធំៗដែលមានផ្លែបានផ្កាហើយ បានជាគេមិនសូវគាស់យកទៅដាំព្រោះវាពិបាករស់ណាស់ ។ វាចាក់ឫសបានជ្រៅកន្លែងណាហើយវាត្រូវតែនៅកន្លែងនោះ ណាមួយខ្លួនវាធំផងពិបាកណាស់មិនដូចអាតូចៗទេដែលឫសវាខ្លីស្រួល... ។

នាងសម្លឹងមុខកម្លោះម្តងសារសងទៀត :

-មើល៍ដើមដូងអញ្ចឹងដែរ គេមិនមែនគាស់អាធំយកទៅដាំឯណា ! គេយកផ្លែវាដែលដុះនោះ... !

-ត្រូវ ! ត្រូវម៉ាច់ !

-អូ ! ម៉ាច់ហើយ ! Bon tres bien !

នាងសួរបងជីដូនមួយម្តងទៀត :

-មើលចិត្តឯងសួរហ្នឹងបានការអី ?

កវីត្បាញអាយនិយាយមួយៗ ថា:

-អារឿងហ្នឹងក៏វាដូចគ្នារឿងស្នេហាដែរ គេស្រឡាញ់គ្នាទាន់នៅក្មេងៗ ដូចយើងទាំងពីរអញ្ចឹង :

អញ្ចឹងបានជាខ្ញុំស្រឡាញ់អាស្រីទាន់នៅតូចនោះណា៎ !

-អ៊ី ស្រឡាញ់ទុកដូចបងប្អូនអញ្ចឹង !

បើស្រឡាញ់ខុសពីហ្នឹង ស្រឡាញ់ម្នាក់ឯងចុះ

នាងនៅតែមានះដូចច័ន្ទរះតែក្នុងពពក ... មិនព្រមបង្ហាញយោបល់ភ្លឺថ្លាសោះ ។

កវីកម្លោះមិនអស់សង្ឃឹមញញឹមតប :

-នៅរឿងមួយទៀត...

-និយាយៗ ចូលទៀតឥឡូវហើយ !

កវីគ្រវីក្បាល :

-ទេម្តងនេះរឿងសៀវភៅ...

-រឿងសៀវភៅយ៉ាងម៉េច ?

-សៀវភៅក្តី របស់ឯទៀតក្តី...

ធ្វើម៉េចឱ្យចំណាំបានថាជារបស់យើងហ៎ ? ហើយធ្វើម៉េចឱ្យគេដឹងថារបស់នោះជារបស់មានម្ចាស់ ?

-ប៉ុណ្ណឹងក៏ធ្ងន់ដែរ ចិត្តឯងតាំងពីរៀនមក ដែលសរសេរផ្លាកឈ្មោះ បិទសៀវភៅទេឬ ?

-មិនធ្លាប់ទេ... (ថ្ងូរ)

-វាមិនដែលកូនសិស្សសាលា ណាគ្មានផ្លាកឈ្មោះនៅសៀវភៅនោះ ?

នាងនិយាយលេងព្រទាំងភ័ក្ត្រឡើងក្រហមព្រឿង ។

កម្លោះរករឿងរមូលពោះ ព្រោះតែសម្ផស្សស្រី ស្រដីតែម្នាក់ឯងក្នុងពោះថា :

-ឱ ! បើអាស្រីស្អាតម្ល៉ឹងៗ នរណាមិនចង់នៅព្រែក គឺឆ្កួតសោះតែម្តង !

ឱថ្កាល់អើយរលាងអ្វីម្ល៉េះតិចលោអត់មិនបាន ហ៊ឺ...

វាចានេះគេគិតនិយាយតែក្នុងទ្រូងទេ ប៉ុន្តែដង្ហើមធំខាងក្រៅឮខ្លាំងតែម្តង ។

-ហ៊ឺ ...

នាងស្រីតូចដែលសម្លឹងតាមបង្អួច ក៏បែរភ័ក្ត្រព្រោះភ្ញាក់និងដង្ហើមធំ ។

នាងស្រីងាកមុខមក... មែន ! ទ្រាំមានបានឯណាកម្លាំងធាតុដុតរោលនាងហើយ ។

ឱថ្កាល់ទាំងគូ ដ៏សល្អអើយក្លិនខុសគ្នាយ៉ាងណាអេះ ? បើតាមស្នានមិនខុសគ្នាទេ ថ្វីត្បិតតែថ្កាល់ឆ្វេងមានប្រជ្រុយមួយជាលំអក៏ដោយ ។

កម្លោះក៏ស្ទុះភ្លែត ចាប់ភ្ជើយភក្ត្រាតារាស្រី ចម្កិតថ្កាល់ពៅពីសីតែម្ខាង គឺអាខាងឆ្វេងដែលមានប្រជ្រុយនោះ ?

ស្រីតូចក្រោកភ្លែត មុខក្រហមដូចគេចាក់លក្ខណ៍កន្ទ្រាក់វាចាតែបន្ទឹតិចៗហើយញ័រៗ :

-ចិត្តឯងឆ្កួតទេហ៎ ? ធ្វើអ្វីអញ្ចឹង ?

-ខ្ញុំឆ្កួតមែនហើយអាស្រី... សូមប្រណីទោសឱ្យផង ក្នុងការផ្តាំឆ្គងនេះ ព្រោះតែស្រឡាញ់អាស្រីពេកបានជាភ្លេចអស់ច្រវាក់ប្រពៃណីជាន់ឈ្លីគុកកម្មទំនៀមទំលាប់ណាំ ហើយមួយវិញទៀតព្រោះតែចង់ឱ្យ

អាស្រីដឹងថាថ្ពាល់នេះជាថ្ពាល់មានម្ចាស់ហើយ ដូចនិយាយរឿងសៀវភៅមិញអញ្ចឹង !

កវីខំរចនាពាក្យលន់តួរប្រើសម្ដីគួរ។ សុទ្ធតែខ្ញុំគេលែងចង្អុលដើមទ្រូងទៀតហើយ ។

តែត្រាណត្រើយមិនស្ដី ស្រស់ស្រីដើរចេញពីក្នុងបន្ទប់ បុរសដើងញ័រមុខឡើងពណិ ប្លែកភ្នែកក្រឡាប់ចាក់ ហាក់ដូចជាភ័យលាយអរខ្លះព្រោះតែរឿងថើបកូនក្រមុំគេនេះ ។

ស្រីតូចខំគេចមុខទុកសម្ដី មិននិយាយរកកវីពេលដែលជួបមុខនាងមិននិយាយរករាល់ពេលប្រទះ ។

កម្លោះពិបាកចិត្តណាស់ព្រោះតែកំហុសខ្លួន មានតែពួនលបលេបទុក្ខលេបសោកម្នាក់ឯងតែប៉ុណ្ណោះ ។

នាងស្រីស្អប់មុខគាត់ហ្នឹងណាស់ ស្អប់មុខហ្នឹងពេកកូវ ជាពិសេសស្អប់ច្រមុះកម្លោះ ដែលបានប៉ះថ្ពាល់ដ៏ក្រពុំរបស់ក្រមុំដែលនាងខំថែអស់រយៈវេលាជាយូរឆ្នាំមកហើយ ។

ពីថ្ងៃនោះរៀងមក កញ្ញាមានការគិតច្រើនណាស់ ។ បញ្ហាមួយម៉ឺនជំពូកលោតវាំពេញបរិវេណខួរក្បាលខ្ចីចំនេះចេះតិចតួចរបស់នាង ។

នាងគិតថាបើបុរសណា បានប៉ះខ្លួនប្រានហើយត្រូវតែ... ជាមួយអ្នកនោះ ដោយមិនឱ្យមានមួយជាពីរឡើយ ។

ណាមួយទៀតនាងគិតថា មិនត្រូវដាក់ចិត្តមានសង្សារមុនម៉ែឪចាស់ទុំទុកដាក់ឱ្យទេត្រូវតែតាំងខ្លួនជាកូនកតញ្ញូស្ដាប់គម្រូអ្នកមានគុណ។

ឱ ! ច្បាប់ទំនៀមទំលាប់ជាគុកកម្មយុវជនអើយ !

ឱ ! សីលធម៌ប្រពៃណីជាច្រវ៉ាក់យុវជនអើយ !

បើកុំតែគេគ្រប់គ្នាខ្លាចអ្នកបន្ទិចកុំអីស្រីខ្មែរ កូនក្រមុំខ្មែរ និយាយឱ្យចំទៅស្រុកខ្មែរ មិនដឹងជាយ៉ាងណាយ៉ាងណីទេ ?

ឯអាស្រីដែលជាបក្សីស្ថិតនៅព្រៃព្រឹក្សាស្រុកខ្មែរ នាងត្រូវមានវិន័យតាមច្បាប់ស្រី ។

កវីឆ្អែតចិត្តក៏បង្ខិតនាទីនេះឱ្យខ្លី សុំទោសស្រី ព្រោះខ្លួនគេត្រូវតែបែកមែកទៅស្រុកស្រែវិញដែរហើយ :

-អាស្រីឱ្យខ្ញុំសុំទោសទៅចុះណា ថ្ងៃមុនខ្ញុំបានជាខុសហួសទៅហើយ ប៉ុណ្ណឹងវាគ្មានសំខាន់អីទេ សូមអាស្រីចាត់ថាជាយល់សុបិន្តអាក្រក់ទៅ បើស្អប់ខ្ញុំណាស់ ! កុំឃើញមុខខ្ញុំគេចអញ្ចឹងគេមើលមកមិនល្អមើលទេ... ។

ស្រីតូចមិនតបក៏យាត្រាហួសទៅ ឯមុខដែលធ្លាប់តែមួម៉ៅក៏ស្រស់ស្រាយបន្តិចដែរ ទាស់តែនាងមិនព្រមបង្ហើបមាត់ស្រដីរកកម្លោះសោះ ។

យុវជនក៏ដាច់ចិត្តឈានជើងឱ្យឃ្លាតញាតិ ជាពិសេសឃ្លាតស្រីដែលខ្លួនស្រឡាញ់ស្មើជីវិត ត្រឡប់មកស្រុកកំណើតវិញដូចណាត់គ្នានិងអាយុនាងដែលឈានវ័យចូលឆ្នាំ ១៦ ល្មម... ។

~៤~

**បន្លាក្នុងទ្រូង**

**មិន** ស្ដីមិនស្ដាប់ ព្រោះថ្កាល់ឆ្វេង
**ស្ដី** តែម្នាក់ឯង ចំបែងក្រៃ
**រក** រឿងប្រលោម ថ្នមសំដី
**បង** សូមអាស្រី ស្ដីតបបង !

លោកតាប្រាក់ដែលជាជីតារួមនៃកម្លោះក្រមុំទាំងទ្វេ ដោយអាយុគាត់កាន់តែជ្រៀលជ្រេដូចព្រះសុរិយា , លោកតាក៏លាចាកលោកនេះទៅទាំងស្រណោះ ហើយទុកឱ្យកូនចៅញាតិមិត្រសោកស្ដាយជាទម្ងន់តាមទម្លាប់នៃមនុស្សជាតិ ។

នៅពេលដែលទៅធ្វើបុណ្យខ្មោចជីតានោះទៀត... អាស្រីឥតមានស្ដីរកកម្លោះចិត្ត សូម្បីតែតិចតួចសោះឡើយ ។ តែណ្ហើយទុកឱ្យគេក្រៀមក្រំ សោកយំក្នុងរយៈវេលាជីតាគេស្លាប់នេះសិនចុះ... ។

នាងស្រីជាមនុស្សដែលខ្លាំងមែន នាងមានចិត្តមានះចង់ឈ្នះរឿងស្នេហានេះ ។

នាងមិននិយាយរកនាយចិត្តទេ បើកម្លោះសួរមួយម៉ាត់ នាងស្ងាត់មួយម៉ោងទើបឮបន្តិចបែបខ្ជិលច្រអូសផង ។

ឱ្យអ្នកស្មានបានចិត្តស្រីប្រភេទនេះ ! ។

ប្រមាណពីរខែប៉ុណ្ណោះ បន្ទាប់ពីតាប្រាក់ធ្វើមរណកាលទៅ...

...លោកសំណាង ក៏ចាប់មានជម្ងឺមហារីកប្រចាំពោះវៀន ដែលយើងដឹងស្រេចទៅហើយថាជម្ងឺនេះ ពិបាកមើលឱ្យជាល្អណាស់ ។

ម្ដាយ ចិត្ត ក៏នាំកូនប្រុសស្រុះស្រួលមូលមតិគ្នាមកពីស្រុកស្រែមកសួរសុខទុក្ខប្អូន ដែលដេកព្យាបាលនៅមន្ទីរពេទ្យកេតុមេលាហើយឮថាស្គមណាស់ទៅហើយ...។

ក្រោយពេលដែលសួរដំណើរដើមទងខ្លះៗ ពីប្អូនរួចហើយម្ដាយចិត្ត ក៏នាំមកសំរាកនៅឯផ្ទះច្បារអំពៅវិញ... ។

នេះមិនដឹងជាលើកទីប៉ុន្មានហើយទេ ដែលកម្លោះជួបមុខស្រីតូចខំនិយាយរកនាងតែឃ្មាងស្មោះស្រីស្រស់មិនចរចាតបឡើយ ។

គូសង្សារនេះ, ថ្វីត្បិតតែគេមិនទាន់ដឹងខ្លួនទៅវិញទៅមកថា គេជាសង្សារប្រចាំចិត្ត... តែគេនៅតែមានចិត្តស្រមៃរឿងខ្លួន ។

ទោះបីយ៉ាងនេះក៏ដោយ ចិត្តនៅតែអន្ទះអន្ទែងជានិច្ច ចិត្តចេះតែសម្លឹងអាស្រី...

ចិត្តនៅតែខំនិយាយរកអាស្រី តែអាស្រីឥតស្ដីសោះ គ្រាន់តែញញឹម ។

នាងញញឹមមួយៗ ធ្វើឱ្យថ្លើមទងបុរសរញ្ជួយចិត្តរកគិតអ្វីមិនយល់ ។

ជាភ័ព្វពេកណាស់ទៅហើយ ឱ្យតែនាងមើលមុខចំហើយញញឹមរកប៉ុណ្ណោះ, ចាំបាច់ឱ្យនាងស្ដីរកអ្វី បើសម្លេងនាងវាដូចសត្វករវីកវរៗ នាំតែទន់លោងដើរមិនរួចទេ ! ។

សំណើចដែលមានមកពីមុន... មកឥឡូវកាលវេលាតម្រូវឱ្យយំក្នុងរយៈពេលមួយប៉ព្រិចភ្នែក ។

ស្មានមិនដល់សោះថា ទូកនៃគ្រួសារអាស្រី ត្រូវសមុទ្រកម្មប្រល័យឱ្យបែកបាក់ដោយព្យុះសង្ឃរាជីវិត...កណ្ដាលទន្លេវដ្ដសង្សារដូច្នេះសោះ ។

លោកសំណាងដែលជាទីអាងនៃគ្រួសារទាំងមូល ដែលជាទំទួលសម្រាប់កូនៗជ្រកគេចពីទឹកជំនន់ជីវិតដែលជាឪពុកដួងចិត្តអាស្រី...ត្រូវក្ស័យលាចាកលោកនេះទៅក្រោយស្នូរយំស្រែកស្មើរបែកទ្វីបលោកនៃញាតិការ សាច់សារលោហិតឥ ។

-អញ្ចឹងសោះហ្ន៎ ជីវិតមនុស្សសត្វរស់ហើយត្រូវស្លាប់ជាធម្មតា ។

-ក្រុមគ្រួសារគេយំទូញបោកខ្លួនសែនចំបែង ចុះម្ដេចក៏ទង់មរណៈឯង សប្បាយចិត្តនិងរេរាំតាមខ្យល់ម្ល៉េះ ?

ទង់រូបក្រពើពណ៌សបក់រវិចមុខគេហដ្ឋាន ។ សេចក្ដីស្លាប់ជាការធម្មតា សត្វលោកគ្រប់រូបតែងទទួលមិនរើសពេលវេលា ។

ប៉ុន្តែចំពោះមរណភាពលោកសំណាង បិតាអាស្រី... មាណវីមានចិត្តស្រឡាញ់គោរពឪពុកធំធេងឥតឧបមា ។ ព្រោះឪពុកមួយរូបនេះខុសគេខុសឯង នឹងថាគាត់ជាកំពូលស្វាមីក៏បានដោយសារថា ព្រោះមួយជីវិតគាត់ គាត់ធ្លាប់ធ្វើឱ្យអ្នកស្រីចំណាប់ស្រក់ទឹកភ្នែកតែមួយតំណក់គត់ ។

ស្រីតូចថ្ងូរតិចៗ សម្រក់ទឹកភ្នែកតក់ៗ :

-ឱ ! ប៉ាគ្មានថ្ងៃទៀតឡើយ ដែលកូនស្រីបានឃើញមុខប៉ាក្រៅពីរូបថតហ៊ឺ !

ទឹកភ្នែកនាងហូរទៀតហើយ ។

លោកសំណាងល្អដាក់អ្នកស្រីចំណាប់ណាស់ ។ ដូច្នេះហើយបានជាស្រីស្រស់ចេះតែព្រួយ តើដល់រូបនាងវិញយ៉ាងដូចម្តេចដែរ ?

បន្ទាប់ពីមរណភាពដ៏សែនក្រៀមក្រំនៃឪពុកមក អាស្រីក៏ដូចជាចិត្តដែលត្រូវជាក្មួយនៃសពដែរ គេទាំងពីរតែងកើតទុក្ខជានិច្ច

រយៈពេលនេះចិត្តនៅរៀន Cours de premaration ដើម្បីប្រឡង Diplome ម្តងទៀត ។ ត្បិតគេជាប់បានត្រឹមតែលើកទី ២ កាលប្រឡងលើកមុន ។

កវីនិងស្រីតូចក៏បានយល់ចិត្តគ្នាស្រេចខ្លះទៅហើយ តែមិនមានវាចា លាក់ទុកក្នុងឱរាវៀងខ្លួន ។

រាល់រាត្រីស្រីមមើមមាយលាយមែនទែនខ្លះ, នាងថ្ងូរហៅឈ្មោះបិតានាងខ្សឹកខ្សួលអួលដើមកគួរឱ្យអាណិតជីវិតកំព្រា... ។

ម្តងនេះចិត្តអត់បានច្រឡើសបើស ប៉ះដៃប៉ះជើងនាងទៀតទេ ខ្លាចនាងឈប់ស្តីរក ។ គេគ្រាន់តែលែបខាយធ្លាយសម្តីថា :

-អាស្រី, ឃើញថាធ្ងន់មែនទែនហើយ !

នាងមាត់តបទាំងស្រពោន :

-ធ្ងន់រឿងអីទៅចិត្ត ?

កវីក៏តម្អូញតទៅទៀត :

-ពីដើមខ្ញុំគិតថា និងធ្វើចិត្តខ្ញុំស្ថិតនៅក្នុងសភាពស្ងប់ស្ងៀមក្នុងអារម្មណ៍មូលមិនរេរា តែទៅឥឡូវ...

-ឥឡូវថាយ៉ាងម៉េច ?

-ឥឡូវខ្ញុំចាញ់ឧបាយកល នៃជីវិតស្នេហ៍ហើយ ខ្ញុំរកដកខ្លួនមិនរួចសោះ !

-ណ្ហើយចិត្ត ! ទៅរៀនកុំមានចិត្តស្រឡាញ់ស្រី កុំបង្កើតធ្វើអ្វីស្នេហានាំតែរៀនមិនទៅមុខទេ...

-ត្រូវហើយអាស្រីប៉ុន្តែចំពោះចិត្តមិនអញ្ចឹងទេ បើស្រីណាស្រឡាញ់រិតតែខំរៀន...

-ហ៊ឺ ! កុំអួត ក្នុងដប់គ្មានមួយផងក៏មិនដឹង គេថាស្រឡាញ់ស្រីខ្លីវិជ្ជា ម៉េចចង់ប្រឆាំងនិងសុភាសិតនេះឬ ?

-ទេ មិនប្រឆាំងទេ, គ្រាន់តែចង់ប្រាប់អាស្រីថាមានខ្លះអាចទៅជាអញ្ចឹង ឱ្យតែស្រីឯណោះព្រមប្រាប់ថាស្រឡាញ់...

-ល្ហើយគ្មានស្រីៗឯណា គេប្រាប់ចិត្តឯងថាស្រឡាញ់ពេញមាត់នោះទេ !

~៥~

## លានរាំងទឹកភ្នែក

**អូន** អើយបងនៅឆ្ងាយពៅហើយ

**សូម** តែត្រាណត្រើយកុំបែកចិត្ត

**ឈ្នះ** គេឈ្នះឯង ឈ្នះញាតិមិត្ត

**ហើយ** សូមតែចិត្ត កុំឈ្នះបង !

រដូវមួយលើកដៃលាចាកទេសភាពទៅ... រដូវមួយទៀតឈានជើងចូលមកដល់។

កម្លោះចិត្តមានក្តីសង្ឃឹមមួយថាគេច្បាស់ជាបានរីករាយមិនខាន។

ចុះម៉េចអញ្ចឹង ?

ក្រោយពេលប្រឡងជាប់ឌីប្លូមហើយ ស្រុកទេសកើតចម្បាំងគ្រិប ។

សាលាធ្លាប់ក្រេបចំណេះ ក្លាយជាផេះអស់រលីងគួរសង្វេគណាស់ ។

កវីមាន់ស្រែត្រូវបង្ខំចិត្ត លាចាកស្រុកកំណើតទាំងអាល័យដើម្បីទៅរៀននៅទីក្រុងភ្នំពេញ។

ឆ្នាំសិក្សា១៩៧០-៧១ ចិត្តក៏មានឈ្មោះក្នុងវិទ្យាល័យមួយ នាទីក្រុងដែលគួរឱ្យធុញថប់ភ្លាម ។

ប៉ុន្តែម្តងនេះគេបាននិយាយនិងម្តាយមីងថា :

-មីង ! ខ្ញុំឆ្នាំនេះមិននៅហ្នឹងទេ កុំឱ្យនាំគ្នាមកជាន់កមីងខ្លាំងពេក... ប្រុសៗបួនប្រាំនាក់ទៅហើយ ដែលត្រូវមកនៅផ្ទះមីងឆ្នាំនេះ... ខ្ញុំគិតថា ទៅនៅផ្ទះពូចន្ទាវិញ !

មីងចំណាប់ តម្លើងសម្លេង :

-ស្អី ! មកនៅត្រឹមម៉ារៀន អញចិញ្ចឹមអ្អែងមិនរស់ឬ ? អ្អែងចង់ទៅនៅឯណា ? កុំគេថាអត់ពីពូអ្អែងទៅ កូនក្មួយអញមិនហៅមិនរកនោះ ?

យកឥវ៉ាន់អ្អែងមកផ្ទះអញវិញមកកុំព្រើលវ៉ី !

នាយចិត្តតប :

-ទេ មិនមែនអញ្ចឹងទេមីង ! ខ្ញុំមកនៅនេះចេះតែបានហើយ តែនៅនេះគ្នាច្រើន ខ្លាចរៀនមិនកើត ព្រោះម្តងនេះ មិនមែនដូចកាលខ្ញុំមករៀន គួរឯណា ? មិនមែនខ្ញុំមានគំនិតថា ខ្លាចអស់អង្ករមីង , មីងចិញ្ចឹមមិនរស់នោះទេ ហើយមិនមែនអត់ពីពូទៅ ខ្ញុំមិនអើ មិនជាន់លែងរាប់រកគ្នាឯណា ... ខ្ញុំនៅមានប្អូនៗ ខ្ញុំប្រាំ ប្រាំមួយនាក់ទៀត ដែលខ្ញុំទុកវាដូចប្អូនបង្កើតអញ្ចឹង !

ត្រង់នេះនាយអាក់បន្តិច ហើយពោលបន្ត :

-ឯការដែលខ្ញុំមិនព្រមនៅទីនេះ ខ្ញុំពិបាកពន្យល់មីងឱ្យច្បាស់លាស់ណាស់ ! មិនដឹងនិយាយយ៉ាងម៉េចឱ្យសម !

-ណ្ហើយទៅនៅផ្ទះអាចន្លាក៏ទៅៗនៅតែឧស្សាហ៍មកលេងណ៎ !

-អូ ជិតបង្កើយនេះ ... ទេតើ !

កម្លោះចិត្ត ចង់នៅសំណាក់ផ្ទះម្តាយមីងមេម៉ាយរបស់ខ្លួនពេកក្នុង ។

ចង់នៅជិតព្រឹកល្ងាចឃើញមុខឆោមពិសីរាល់ថ្ងៃ ។

ប៉ុន្តែមិនអាចរស់នៅបញ្ចុះកំពង់ រហូតដល់ទៅកូនសិស្សប្រុសៗហើយកម្លោះៗទៀត បួនប្រាំនាក់នោះទេ ។ មិនមែនខ្លាចរៀនមិនកើតឬរៀនមិនកើតឡើយ ។

តាមពិតគេខ្លាចមានការឈ្នានិះគ្នាទៅវិញទៅមក

ព្រោះម្ខាងជាសាច់ញាតិខាងមីង ... ឯខ្លួនឯងជាខាងខ្មោចពូ ។

រឿងនេះ អាជ្ញាកណ្តាលត្រូវតែមាននិន្នាការ ... ។

យុវតីអភ័ព្វ ... ក្រោយពេលដឹងថាចិត្តដែលត្រូវជាបងជីដូនមួយត្រូយចិត្តខ្លួនពួនមុខមិនព្រមមកនៅលំនៅនាង , នាងក៏សួរ :

-ចិត្តឯងម៉េចមិននៅហ្នឹង ម៉េចទៅនៅឯណាវិញ ?

កវីពេញដោយក្តីសង្ឃឹមញញឹមតប :

-នៅផ្ទះពូចន្លាក៏មិនជាឆ្ងាយប៉ុន្មានដែរ ខ្ញុំចង់នៅជិតណាស់ប៉ុន្តែខ្លាចតែមានរឿង ...

-ខ្លាចមានរឿងអីទៅ ?

-នៅហ្នឹងប្រុសៗច្រើនពេក ខ្លាចច្រណែននិន្នាឈ្នានិះគ្នាណ៎ ...

ណាមួយឯងរូបមិនសូវស្អាត នៅនាំតែខ្មាស់គេទេ ទុកនាទីនេះឱ្យគេចុះ !

-ណ្ហើយចិត្តអើយកុំនិយាយអញ្ចឹងនោះ ។ អាស្រីមិនមែនរបស់សម្រាប់គេដណ្តើមគ្នាលេងនោះទេ បេះដូងស្រោបដែកណាំ !

បើថាមិនចង់នៅទេក៏ហីទៅ កុំរូបស្អាតមិនស្អាតស្អីនោះ ។ ម៉េចស្មានថាគេមិនដឹង ទៅផ្ទះពូចន្ទាឱ្យបានជិតមី ... មួយ ...

ហ៊ឺ មិនចង់ថាទេ ...

-ទេអាស្រីច្រឡំហើយ តាមពិតខ្ញុំមិនចង់នៅទីនេះ ខ្លាចថែមអាស្តាំមួយចំហៀងទៀតទៅ នាំតែអត់ស្តីរកទៀតទេ... ខ្លាចបីខែទៀត !

-អូ បើហ៊ានប៉ះថ្ពាល់ស្តាំទៀត ម្តងនេះច្បាស់ជាតមមាត់មួយឆ្នាំ

នាងនិយាយបែបអៀនព្រោះភ័ក្រ្តក្រហម ។

ទោះបីចិត្តឃ្លាតទៅនៅផ្ទះពូម្នាក់ទៀត ឆ្ងាយបន្តិចពីកន្លែងឧត្តមដួងចិត្តហើយក្តី ក៏រឿងស្នេហ៍គេឥតបានបំភ្លេចចោលទេ មានតែខំចងក្រងឱ្យមាំមួនទ្វេឡើង ។

គេមិនសូវមកលេងញឹកពេកទេ ប៉ុន្តែគេឧស្សាហ៍មកមើលមុខស្រីតូចគេដែរ ព្រោះគេខ្លាចណាស់ពាក្យថា "ឆ្ងាយណាយចិត្ត" ។...

ថ្ងៃអាទិត្យនេះ ជាថ្ងៃទំនេរ ...

មាណពខំរូតរះប្រញាប់ ដើម្បីទៅលេងផ្ទះប្អូនស្រីសម្លាញ់ចិត្ត...។

និយាយលេងពីនេះពីនោះរួចហើយ ក៏តាំងធ្លាក់ដល់រឿងស្នេហា។

ចៅចិត្តពោលថា :

-ហ៊ឺ, ឯងឃើញគេញញឹមដាក់គ្នា ឃើញគេធ្វើការផ្គាប់ចិត្តមីងដូចជាអស់សង្ឃឹមណាស់ !

ឱ! ហេតុតែគេនៅជិតហ្ន៎ !

នារីសម្លក់ភ្នែរ :

-រួចយើងក្រែងម៉ាក់ហៅឱ្យនៅដែរ ម៉េចស្រាប់តែទៅនៅឯណារួចមកថាអញ្ចឹង ?

-ណ្ហើយទុកជានៅជិត ក៏ចិត្តឯងហ្នឹងវាអន់ដែរមិនឈ្នះគេទេ ឯងវាមិនសូវពូកែផ្គាប់ចិត្តនោះ ...

នារីសង្រួមសម្តីឱ្យស្លូត :

-ណ្ហើយចិត្តអើយ ! ផ្តាំទៅវិញផងថា កុំសង្ឃឹមអី ...

ចិត្តឯងសព្វថ្ងៃ ដែលឃើញឯណេះនិយាយរកវាទេ ? អាណា ?

-អាទូចណាំ !

-រួចម៉េចបានជាមិនស្តីរកវា ?

វាម៉េច វាស្អីៗដូចខ្ញុំដែរទេមើលទៅ ?

(រឮករឿងចើបថ្ពាល់ឆ្វេង)

នាងសម្លក់ :

-អាណិតបានជិតទៅ !

-វាម៉េចវាខុសអីអញ្ចឹង ?

នាងរៀបរាប់ :

-ថ្ងៃមុនគេផ្ញើសំបុត្រតូចមួយញាត់ក្នុងកាបូបខោដៃខ្ញុំ

-សំបុត្រនោះថាម៉េចខ្លះទៅ រួចឥឡូវនេះទៅណាហើយ ?

-ហែកចោលបាត់ហើយ គេដាក់ថាបងស្រឡាញ់តែអាស្រីមួយ បងខំរៀនសព្វថ្ងៃ ក៏ព្រោះតែអាស្រីដែរ សូមអូនស្ដាប់ចិត្តផង ហត្ថលេខា បុរសអភ័ព្វ !

កម្លោះសើច

-អាហ្នឹងដល់ប៉ុណ្ណឹងហ្ន៎ !

-យកឱ្យម៉ាក់មើល ម៉ាក់ជេរវាមិនតិចទេ ។

-យីម៉េចក៏ធ្វើកម្មធ្វើពៀរគ្នា ម្ល៉េះអញ្ចឹងគ្រាន់តែដឹងម្នាក់ឯងទៅ មិនបានហ៎ ? ចំហើយនេះ !

នាងសម្លឹងចំមុខម្ដងទៀតហើយពោល :

ប្រុស១ប្រហែលគិតថា ស្រី១អៀនខ្មាស់ណាស់ លាក់រឿងសម្ងាត់ពីបុរសដែលសុំស្រឡាញ់ខ្លួន មានរឿងសរសេរសំបុត្រជាដើម ...

អូស្រីណាមិនដឹងទេ ឯណេះកុំហាក់... បើមិនជឿសួរម៉ាក់មើល...!

កវីតម្អូញថា :

-រិះខូចការអស់

ឯងប្រុងផ្ដងសំបុត្រមួយដែរកុំអីស្រេច !

-នៅសាលាអញ្ចឹងដែរ

អាមួយនោះឈ្មោះហ៊ីប្រាប់ទៅក៏មិនស្គាល់ដែរ វារៀននៅ A វាផ្ញើសំបុត្រតាមអាមួយនោះរៀនជាមួយ ... យកមកឱ្យមានអី ... យកទៅជូនលោកគ្រូបាត់ !

កវីសើចទៀត :

-ហ៊ឹចឯកម្មពៀរមែន នេះបានហៅនារី បេះដូងដែក !

នាងបន្ថែម :

-បើមិនដែកឯណា ស្អីអូនបង ... បងអូនអីស្ដាប់មិនបានទេ ! ។

-នែអាស្រីហា៎

ញញឹមដាក់គេខ្លះទៅ វាមិនមែនខាតអស់ប៉ុន្មានកញ្ជើនោះទេ ?

និយាយអញ្ចឹង នៅមួយទៀត ចេញពីរៀនមកម្តង PM និងទាហានផែកមុខវត្តនិរោធដាក់ផ្កាចំប៉ាក្នុងកាតាបញ្ជូយ ថាខ្នាញ់ដល់ហើយ ...។

កម្លោះបង្អួសតាមរឿង :

-អូ ! ជាកិត្តិយសមួយហើយដែលមានគេចោមស្រឡាញ់ ច្រើនព្រោះយើងល្អបានជាគេស្រឡាញ់ ...

-ហ៊ឺ មិនជួលឱ្យស្រឡាញ់, មិនខ្វីសរសើរទេ

-នែអាស្រីហ៎ា កុំសូវស្អប់ប្រុស១ពេក កុំឱ្យប្រុស១ ខឹងណា ...

ប្រុស១ តែគេប្រាថ្នាអីហើយ តែគេចង់បានហើយ, គេគ្មានស្គាល់ងាប់ទេ ។ ចង់អស់ក៏អស់ទៅប្រយ័ត្នណាំធ្វើស្ទៀម១ ទៅល្អជាង ។

នាងញញឹមបញ្ចេញសំលេងសារិកា :

-មួយជាតិនេះសច្ចាយកឈ្នះប្រុស១ ទាំងអស់មិនឱ្យមានសោះអារឿងសង្សារស្អីគេហ្នុងទេ

មួយជីវិតនេះចាញ់តែម៉ាក់មួយគត់ និង ...

កម្លោះសើចស្រស់បន្ថែម :

-និងប្តី ?

-និងសេចក្តីស្លាប់តែប៉ុណ្ណោះ ព្រោះវាថាបញ្ញត្តិនៃធម្មជាតិទៅហើយ ។

មាណពលើកដៃ :

-សូមឱ្យបានសម្រេចចុះ តែកុំភ្លេចថា មានថ្ងៃណាមួយចាញ់ប្រាកដជាមិនឈ្នះ !

-ថ្ងៃក្រោយទៅមើលចិត្តខ្លួនឯងមិនហ៊ានថាដែរ ... ។

-ទេមិនហ៊ានថាអី ... ?

ចាញ់គ្មានថ្ងៃឈ្នះតែម្តង ចាញ់ប្តីណា៎ !

-អាណិតទៅ

-ហ៊ឺ ! អ្នកឈ្នះ !

-ឈ្នះហើយ !

~៦~

## ព្រួយចិត្តត្បិតព្យាតិ

**យក** ចិត្តទៅធ្វើជាថ្នាំ

**បង** សូមវរមិត្រឆ្លើយឱ្យច្បាស់

**ខ្លាស់** ញាតិ, បងក្រ ស្រីល្អខ្លាស់

**គេ** ស្អប់បងណាស់ បងសូមលា !

វាសនាគឺការកសាងមែនហើយ ! សេចក្ដីស្នេហាក៏ជាការកសាងដែរ ! មិនថាអញ្ចឹងអាស្រី ?

ស្នេហាខ្ញុំ ខ្ញុំខំកសាងអស់រយៈពេលពីរបីឆ្នាំរួចមកហើយ មិនគួរឡើយពួកនេះមកឆាឆៅសោះអញ្ចឹង ?

មើលវាសរសេរសំបុត្រលេងចំអំបែងក្បាលឯងតែម្ដង !

-គេថាចិត្តឯងដើមទ្រូងដប់ហត្ថគេថាជាយុវជនឈាមរាវ

-នែអាត្រង់នេះ គេថា ខ្ញុំជាកវីវោហាពូកែជាងគេ ១លានដងឃើអានេះខ្លាំងជាងអាទូចឆ្ងាយណាស់ ស្រឡាញ់អាស្រីឯណោះដៀលឯងឯណោះ ...

សំបុត្រហ្នឹងឱ្យតាំងពីអង្កាល់ ?

-ឱ្យតាំងពីថ្ងៃប្រាំពិលម្ល៉េះ

-ចាំសរសេរសំបុត្រទុកឱ្យវាមួយមើល៏

-ណ្ហើយចិត្តអើយកុំនាំរឿងនោះ ...

មកទល់និងពេលនេះ គេទាំងពីរចាក់ទឹកមិនលិចទេមានរឿងអីក៏គេប្រាប់គ្នាដែរ ។

នរណាលួចស្រឡាញ់នរណាក្នុងសំបុត្រ ក៏អាស្រីមិនប្រាប់ចិត្តទាំងអស់ សូម្បីតែរឿងអាថិកំបាំងទាក់ទងខាងផ្នែកស្រ្តីភេទក៏នាងប្រាប់កម្លោះគ្មានចន្លោះដែរ ។ បើអញ្ចឹងមិនឱ្យកម្លោះស្លាប់ចិត្តស្លុកឯណា ?

តាំងពីចិត្តឃ្លាតទៅបម្រើជាតិក្នុងកងទ័ព ព្រោះកាលៈទេសៈនិងឈាមខ្មែរដង្ហោយហៅ... គេក៏មិនបានឱ្យឃ្លាតឆ្ងាយពីពៅពន្លកស្រីតូចតន់ឱ្យយូរពេកដែរ ។

គេតែងស្កាត់ទៅរកជួបមុខនាងរាល់ពេលដាច់ខែ ត្បិតតែគេនៅឆ្ងាយនាងមួយរយផ្លាយគីឡូម៉ែត្រក៏ដោយ ។ (កំពង់ចាម)

ពេលជួបគ្នាម្ដង រាត្រីកាលមកដល់ អាស្រីមិនសូវខ្វល់ ចាប់ភ្លឹកនឹករកដំណេកប៉ុន្មានទេ ...

នាងស្ដាប់, នាងសំណេះសំណាលលេងពីនេះពីនោះមិនចេះអស់មិនចេះហើយ ។

-អាស្រីនៅកំពង់ចាមឯណោះ យុទ្ធនារីក្រមុំស្អាត១ ដល់ហើយ !

នាងបណ្ដោយ :

-ម៉ិចមិនដណ្ដឹងយកធ្វើប្រពន្ធមួយទៅបើស្អាត១ !

-តែស្អាតយ៉ាងណា ក៏មិនដល់អាស្រីបុប្ផាស្ពារអំពៅនេះដែរ !

នាងវាចាតបព្រោះចំរើននាង :

-កុំនិយាយណាំប្រយ័ត្ន !

ម៉ាក់មិនមែនឱ្យទេ ! គេចង់នៅរៀនទៀត !

-អូំ គ្មានរៀនដល់អាយុប៉ែតសិបទេ តែស្អែកហ្នឹងមេក្រូរហ៊ឹម ហើយ !

-អាណិតទៅ !

មិនមែនឃើញតែបុណ្យសក្តិនោះទេ បើអញ្ចឹងម៉េចម៉ាក់មិនឱ្យសក្តិពីរប៉េអឹមដណ្តឹងថ្ងៃមុននោះទៅ !

-សក្តិពីរចាស់ ប៉ុន្តែសក្តិមួយក្មេង ?

-កុំនិយាយនាំតែក្តៅទេ !

កម្លោះបាត់មាត់ដូចគេចុក ... ។

អ្នកហាក់ដូចជាខ្លាចនារីណាស់, អ្នកគោរពនាងណាស់ ។ តែគេក៏ចង់ឱ្យនាងខ្លាញ់ណាស់ដែរ ...

-អាស្រីតាំងពីចូលឆ្នាំនេះមកមានគេចោមស្រឡាញ់សម្បើមតែម្តង !

ព្រោះអាស្រីស្អាតដូចសិតារបស់ព្រះរាមអញ្ចឹង ...

-ណើ្បយកុំសរសើរនោះគ្មានលុយជួលទេករី

-ប៉ុន្តែក្តីប្រតិព័ទ្ធ របស់ក្រុងរាពទាំងឡាយតូចជាង និងស្មោះមិនដល់ព្រះរាមទេ ឯព្រះរាមសម័យនេះគឺចិត្ត...ខ្ញុំ... !

នាងអៀនឡើងមុខក្រហម តែនាងមិនព្រមបញ្ចេញពាក្យស្នេហាឱ្យកម្លោះយល់សោះ ។

នាងស្រីនៅមានចិត្តមានះមួយព្រមទាំងការខ្មាស់អៀនផងដែរ...

នាងមិនព្រមប្រាប់កម្លោះវិញ ថានាងក៏មិនស្អប់ចិត្តដែរ ប៉ុន្តែហារនិយាយភាសាអីបើនាងជាស្រីអញ្ចឹង ! ។

ហើយនាងក៏បានសច្ចាទុកក្នុងដួងចិត្តនាងស្រេច ថានាងត្រូវការចង់បានតែប្រាណចិត្តមួយ មកជាគូគ្រងនាជីវិតនេះ ។

អ្នកណាមិនសង្ឃឹម អ្នកញញឹមស្ទើរធ្លាយថ្ពាល់ចៅចិត្តសប្បាយឥតប្រៀប និងកាយវិការស្នេហា ដែលកញ្ញាមានមកលើអ្នកតាំងពីដើមរៀងមក ថ្វីត្បិតតែគេមិនបានឮនាងប្រាប់នូវពាក្យថាព្រមស្រឡាញ់ក៏ដោយ ។

យុទ្ធជនបដិវត្តក៏រំអុកឱ្យម្តាយមកសាកល្បងស្ទើចិត្តប្អូនស្រីបន្ថែមលើចិត្តសណ្តោស ដែលនាងធ្លាប់មានរួចហើយ ។

ថ្ងៃ ២៣ សីហា... ១៩៧១

ម្ដាយចិត្តទៅដល់ច្បារអំពៅ ហើយសំណេះសំណាលលេងពីនេះពីនោះអស់ចិត្តអស់ចង់ ។

អ្នកស្រីសុរិយ័នម្ដាយកវីចិត្តក៏យល់សាច់ការ :

-មីនាងហាំ !

គាត់និយាយទៅរកប្អូនដែលត្រូវជាម្ដាយស្រីតូច ។

-អញសព្វថ្ងៃកាន់តែចាស់ទៅហើយ ណាមួយអាចិត្តធ្វើទាហានផង...អញគិតថារកប្រពន្ធឱ្យវាហើយ អើទាន់អញនៅរស់...ណាំ !

ខណៈនេះនរណាអាចស្មានថា អ្នកស្រីចំណាប់មានវាចាដូច្នេះ :

-អ្នកឯងទៅសួរក្មួយមើល បើវាព្រមខ្ញុំមិនថាអីទេ...

អាការស្រឡាញ់គ្នាស្រេចនៅលើកូនទេ ... ខ្ញុំមិនមែនសម្រេចខ្លួនឯងឯណា,

បើវាស្រឡាញ់ក៏មិនដឹងបង្ខំវាអាម៉េចដែរ បើខ្ញុំវិញគ្មាននរណាបង្ខំបានទេ ...

សូមបញ្ជាក់ថា: បានជាគាត់ចាប់និយាយភ្លាមស្រាប់តែមកដល់រឿងចិត្តនិងអាស្រីព្រោះពីមុនៗមកគាត់ចំអែចំអន់គ្នាលេងរួចមកហើយ ។

តែនេះក៏ដូចជាគំម្រោងការពិសេសមួយ ដែលអ្នកស្រីចំណាប់ដឹងចិត្តកូនស្រីរួចមកហើយ ។

អ្នកស្រីសុរិយ័ន្តហៅក្មួយស្រីសម្លាញ់មកស្នើ :

-ក្មួយអាំ ! អ៊ំគិតដណ្ដឹងក្មួយឯងឱ្យទៅអាចិត្ត តើក្មួយឯងថាម៉េច ?...

-ដណ្ដឹងខ្ញុំ ?

-អើទាន់អ៊ំនៅមើលមុខកូនប្រសារច្បាស់ណាំ !

-ទេមិនកើតទេអ៊ំ ( នាងតបអ្នកសុរិយ័ន្ត)

-មិនកើតយ៉ាងម៉េច ?

នាងដាក់មុខចុះបន្តិចពោលបន្ត :

-ខ្ញុំមានសង្សាររួចមកហើយ !

-មានសង្សាររួចហើយ !

-ចាំនៅរៀនសាលាជាមួយគ្នា ...

អ្នកមីងសុរិយ័ន្តលើកដៃគក់ទ្រូង សម្រែកនិយាយស្ទើរក្លាយជាយំ :

-ហ៊ឺ អាចិត្ត !

អាមានតែភ្នែកអត់ប្រស្រី នៅជាមួយគេយូរហើយមិនដឹងថាគេមានសង្សាររួចអួតថាគេស្រឡាញ់វាទៀត ...

សម្លេងនេះកញ្ឆក់អ្នកស្រីចំណាប់ឱ្យប្រញាប់មក :

-មើលមីស្រី ង៉ែងមានសង្សារមែនឬអី មើល៍ឆ្លើយមកមើល ? ។

ស្រីតូចភ័យញ័រមាត់ :

-ទេម៉ាក់ខ្ញុំគ្មានសង្សារឯណាទេ ។ តែខ្ញុំចេះតែឆ្លើយទៅកុំឱ្យអ៊ំសួរតទៅទៀត ព្រោះខ្ញុំចង់នៅរៀនណា៎ !

អ្នកស្រីសុរិយ័ន្តលូកសម្តី :

-នែក្មួយ ! អ៊ំស្មើរក្មួយឯងមិនមែនបង្ខំឱ្យក្មួយឯងយកវាហើយរៀបការស្អែកនេះឥឡូវឯណា !

ចង់រៀនទើសដល់ណាដល់ណើក៏រៀនទៅ គេអាចចាំបានឱ្យតែក្មួយឯងឆ្លើយថាព្រមម៉េចក៏ក្មួយឯងនិយាយ...អញ្ចឹងទៅវិញ ?

អ្នកស្រីចំណាប់ប្រាប់កូន :

-មើល មីស្រី ឆ្លើយមួយម៉ាត់ឱ្យដាច់មើល ម៉េចឮអ៊ំសួរ ទេ ?

-ខ្ញុំមិនយកទេអ៊ំ យកបងប្អូនឯងអញ្ចឹងខ្មាស់គេណាស់ !

-ហ៊ឺ ... ( អ្នកស្រីសុរិយ័ន្តដកដង្ហើមធំ)

អ្វីដែលកើតឡើងក្នុងថ្ងៃនេះ មិនដូចអ្វី១ដែលកើតឡើងកាលពីថ្ងៃមុននោះ គឺវាមិនទៀងទាត់ជាធម្មតា ! រឿងនេះប្រាកដណាស់ ។

មិនស្មានថាស្រីអាចផ្លាស់ចិត្តនិងសម្តី បាតដៃជាខ្នងដៃដូច្នេះសោះ ។ ពិបាកមែនចិត្តនិងសម្តីស្រី ។

ល្ងាចបន្តិប្រមាណជាម៉ោងប្រាំកន្លះ កម្លោះចិត្តស្តាយបង្វិចក្តីសង្ឃឹមទាំងញញឹមទៅច្បារអំពៅ ...

លុះទៅដល់ម្តាយគេខ្សឹបប្រាប់ថា គេមិនយកឯងទេ គេមានសង្សាររួចមកហើយ ។ ទោះឮដូច្នេះក៏ចិត្តនៅតែមិនអស់ចិត្តទៀតគេនៅចាំបញ្ជាក់ឱ្យបានផ្ទាល់មាត់មើល តើវាដូច្នេះមែនឬទេ ! ។

ព្រលប់យប់សន្ធិយា រាត្រីកាលគ្របសំពត់ពណ៌ខ្មៅពាសពេញផ្ទៃមេឃរាត្រីនេះមានភ្លៀងផង ខ្សែភ្លើងមួយជួរនេះក៏ដាច់អស់ទៅហើយដែរ ។

ចាស់១ចរចាគ្នា ដោយស្ងាត់ស្ងៀមក្នុងបន្ទប់ទទួលភ្ញៀវ ឬបន្ទប់ដែលចិត្តធ្លាប់បង្រៀនអាស្រី កាលពីរបីឆ្នាំមុន ។

គេទាំងពីរនាក់ស្ថិតនៅក្នុងភាពងងឹតសូន្យក្រោយពេលទៀនមួយកំណាត់ខ្លីរលត់ទៅ ។ ក្នុងបន្ទប់មួយដោយឡែកស្ថិតនៅចំពីមុខគ្នាទៅវិញទៅមក គេរក្សាកិត្តិយសជានិច្ច ងងឹតស្ទើរចាក់ភ្នែកពុំយល់ផ្លេក កន្ទាររវះផ្ទៃមេឃហែកបង្ហាញរស្មីម្តង ១ ។

ចិត្តចាប់ផ្តើមសារសង :

-ថ្ងៃមុិញឮម៉ែប្រាប់ថាអាស្រីឯងមានសង្សារ តើពិតហ៎ ?

នាងតបទាំងមិនឃើញបបូរមាត់ :

-អត់ទេ, ហ៊ានស្បថឱ្យស្លាប់ទៅ តែចេះតែឆ្លើយទៅ ...

-គួរដែរបើអញ្ចឹង អាងតែមានមាត់ចេះតែថា បើមិនស្រឡាញ់ទេហើ ចាំបាច់ថាមានសង្សារធ្វើអី ? ។

-ចិត្តឯងគួរយល់ចិត្តខ្លះផង ...

យកបងប្អូនឯងធ្វើប្ដីប្រពន្ធខ្មាស់គេណាស់ កុំឱ្យញាតិគេនិន្ទាណា៎, គេដណ្ដឹងថ្ងៃមុនមិនព្រមយក មកចាំយកបងប្អូនឯង ណាមួយបងប្អូនឯងប្រជែងគ្នាដល់ទៅបីនាក់ឯណោះ ហ៊ឺខ្មាស់គេណាស់ !

-ខ្មាស់គេ ! ?

-ហ្នឹងហើយអ្នកស្រុកផ្ការមួយមិនយកតែទាំងអស់ហ្នឹង

-ឱ ធ្វើម៉េចឯងសក្តិតូចតាច គេរកតែសាស្ត្រាចារ្យឯណោះ ! ។

-ឆ្លើយឯណោះមិនមែនអញ្ចឹងទេ ។

ទាំងពីរនាក់ស្ងាត់បន្តិច :

-ឥឡូវមុនពេលបែកគ្នានេះខ្ញុំសុំសួរ អាស្រីមួយមាត់ដើម្បីកត់ចំណាំទៅថ្ងៃក្រោយ ...

តើពីរឆ្នាំមុនស្រឡាញ់ខ្ញុំទេ ?

នាងអេះអុញ :

-"OUI" នាងឆ្លើយជាភាសាបារាំង

-ចុះឥឡូវម៉េចក៏ឈប់ស្រឡាញ់ ?

-ព្រោះឯងសាវ៉ាពេក !

-សាវ៉ា ?

-ហ្នឹងហើយ ! របិលរប៉ូចឃើញត្រង់ណាស្រឡាញ់ត្រង់ហ្នឹង ។

-ហ៊ឺ ... ចុះគំនរស្នេហ៍ដែលរាយប៉ាយហើយគរសារជាថ្មីវិញបានទេ ?

-គរសារជាថ្មីមិនបានទេ

-ជាមួយប្រុសណាទៀតបានហ៎ !

ប្រុសណាក៏អត់គរវិញដែរ ពាក្យថាសង្សារមួយមិនឱ្យយល់ទេ ... ។

ច័ន្ទធ្លាប់ចរក្នុងចិត្តជះរស្មីស្រទន់ នាពិភពស្នេហ៍នេះជឿថា ក្នុងវាយល់សប្តិហ្នឹង ស្នេហ៍គេមិនមានឮពាក្យថាបាក់បែកដូចចង្កៀងខ្វះប្រេងនោះទេ ។ ដួងចិត្តកវីដែលធ្លាប់ជោគជាំដោយទឹកមន្តស្នេហ៍ស្រីត្រូវរីងខះបែកក្រហែងដូចដីខែប្រាំង ។

កម្លោះចិត្តក៏កាន់តែជ្រុលខ្លួនស្លុង ទៅក្នុងពិភពដ៏អស់សង្ឃឹមហើយ ។

## បន្ទូលចាំសោក

**ថ្ងៃ** ឃ្លាតលាញាតិលារូបស្ងួន
**ជួប** មុខនឹមនួន ពួនលែងស្តី
**ថ្ងៃ** មួយអូនច្រៀងផ្តាំកវី
**ព្រាត់** ទាំងអាល័យ ព្រោះស្រីស្ងាត់ ! ។

តាំងពីយប់ថ្ងៃទី ២៣ នោះមក ឃុំនិងបង្គងក៏បែបគ្នាអស់រយៈពេលដ៏យូរ ។ ឃុំព្រាត់បង្គងមកនៅល្ហល្ហេវក្នុងវាលវត្តសង្សារគ្មានទីកំណត់ ។ យុវបុរសកំសត់ពោលតែឯកឯងថា :

-អាស្រីមិនគួរយើងឃ្លាតពីគ្នាសោះ ! ពេលនេះ បងលែងឃ្លានហើយបាយ លែងស្រេកហើយទឹកលែងនឹកហើយដំណេក បងនឹកតែរូបស្រី ...

តើអូនមានមន្តអីដែលធ្វើឱ្យបងបែកមិនបាន :

-ទេ ខ្ញុំត្រូវតែបំភ្លេច, ខ្ញុំត្រូវខំរើបម្រាស់ឱ្យផុតពីក្រញាំស្នេហាហើយចារឹកនូវគំនុំសងសឹក ឥតព្រំដែន ។ រនាបបាក់គេយករនាបជួសចុះ

បេះដូងបើប្រេះឆាហួសទៅហើយ ថ្នាំព្យាបាលជំងឺចិត្តគ្មានលក់នៅឱសថស្ថានទេ មានតែការសងសឹកទើបជាឱសថសួរគ៌ា ។

ទេប្អូនស្រីខ្ញុំ, សាច់ញាតិខ្ញុំ ខ្ញុំធ្វើអញ្ចឹងមិនសមទេ បើកុំតែផែនដីមូល កុំអីខ្ញុំដើរឱ្យផុតព្រំដីឱ្យវាធ្លាក់ស្លាប់ទៅចុះ, ព្រោះខ្ញុំលែងចង់ត្រូវការឃើញមុខមនុស្សស្រីខ្វះសុទ្ធចិត្តតទៅទៀតហើយ ។

ស្តាយណាស់ពាក្យសម្តីពូ ដែលមុនស្លាប់ផ្តាំឱ្យយើងជួយគ្នា ។ យើងទុកឱ្យកវីអស់ក្តីសង្ឃឹម លបជេរលបច្រៀងអត់ភ្លេងតែម្នាក់ឯងសិនចុះ ...

តើអាស្រីឯណេះវិញតាំងពីប្រុសស្នេហ៍ឃ្លាតទៅយ៉ាងម៉េចដែរ ។ នាងគេងមិនលក់ នាងបង្ហូរទឹកភ្នែកមិនខុសពីចិត្តប៉ុន្មានដែរ ។

នាងក៏ស្រឡាញ់ចិត្តណាស់ដែរ តែហេតុដែលបណ្តាលឱ្យនាងឆ្លើយប្រកែកនោះ :

-បងចិត្ត ! សូមបងកុំយល់ច្រឡំឱ្យសោះ អូននៅមានចិត្តស្មោះលើបងឥតក្បត់ទេ ។ ឯការដែលអូនឆ្លើយនេះគឺតម្រូវចិត្តគ្រួសារអូនសិន ...

ឱ្យខ្ញុំរេទៅខាងណា បើម្ខាងសង្សារម្ខាងញាតិសន្តាន អូនមិនព្រមយកប្តីក៏ព្រោះតែនៅចាំបង តែអូនមិនទាន់ព្រមយកបងក៏ព្រោះតែអូនមិន

យកប្ដីមុននោះដែរ គេមុនសក្ដិ១ សក្ដិ២ , ដល់ខ្ញុំព្រមយកបងភ្លាមគេសើច និន្ទាឱ្យអូន ។ តែចាំចុះអូនមិនបំភ្លេចបងទេ ណាមួយគេប្រាប់អូនថា : បើអូនជាកូនច្បងយកប្ដីសក្ដិតូចតាច តើប្អូនស្រី១ក្រោយ១វាបានប្ដីប៉ុណ្ណា ហេតុនេះហើយទើបអូនទ្រាំឆ្លើយសិនចុះ ។ មិនស្មានថាបងលែងមករកអូនសោះ សំបុត្រដែលអូនសរសេរទុកឱ្យបងក៏មិនឃើញម្ចាស់ដួងចិត្តមកទទួល ... បងចិត្ត !

ពេលមួយ , កវីអស់ក្ដីសង្ឃឹមក៏ឈានជើងជាន់ដែនដីច្បារអំពៅទាំងបង្ខំព្រោះកាតព្វកិច្ច !

ម្ដងនេះគេមិនខ្ចីមើលមុខអាស្រីទេ តែចង់បញ្ជាក់ថា គេចង់តែដើរឱ្យផុតពីផែនដីនេះ ។

នារីអភ័ព្វស្ទើរតែប្រេះទ្រូងទៅហើយ នាងសួរញាតិមិត្រស្រី១ថា:

-បងញ៉ឹបដឹងទេ ហេតុអីក៏ចិត្តលែងស្ដីរកខ្ញុំអញ្ចឹង ?

-ដឹងអី ប្រហែលគេខ្មាស់អាស្រីឯងហើយ ...

-ខ្មាស់អីប្រហែលខឹងនិងខ្ញុំហើយ ...

-ទេ មានរឿងអីគួរឱ្យខឹង ?

-ហ៊ឺ បងឯងមិនដឹង ខ្ជិលដឹងអី !

ថាហើយនាងក៏ច្រៀងបទនាងប៉ែន រ៉ន គឺបទអូននៅតែស្រឡាញ់បានជួបហើយម៉េចក៏ធ្វើកន្ដើយនោះ ។

ថ្ងៃបន្ទាប់នាងញ៉ឹបក៏បានប្រាប់កវីចិត្តថា :

-ចិត្តហា៎ ! អាស្រីគេថាចិត្តឯងខឹងនិងគេ រឿងអ្វីបានជាមិនស្ដីរកគេ ?

យុវជនសើចតប : ខឹងរឿងអី ? ហ៎ះ ហ៎ះ ហ៎ះ ?

-ឱ ! នែ ! អាស្រីមួយថ្ងៃ១ ច្រៀងតែបទហ្នឹងទេ ...

-បទអីទៅ ?

-បទអូននៅតែស្រឡាញ់ណា៎ !

គេកើតទុក្ខទៀតហើយ ! ឱ្យចិត្តបំភ្លេចម្ដេចបាន ថ្វីត្បិតតែគេខឹងតែគេក៏នៅតែស្រឡាញ់ដែរ ។

តែកម្លោះឆ្ងល់ណាស់និងសម្ដីអាស្រី ។

ក្រោយមកបីខែកន្លងផុតទៅ ការរង់ចាំរបស់ចិត្តក៏នៅតែឥតជោគគឺស្ថិតនៅក្នុងភាពល្ហល្ហេវដដែល ។

រដូវមានផ្លាស់ប្ដូរ ចិត្តស្នេហ៍របស់គេគ្មានប្ដូរទេ តែបើក្ដីសង្ឃឹមវិញប្រៀបដូចសុបិន្ត ឬដូចរស្មីផ្លេកបន្ទោរ ។ ប៉ុណ្ណោះ ឱ្យរស់នៅ... តទៅទៀតដូចម្ដេចបាន ?

កម្លោះដឹងថាតម្លៃនៃក្ដីស្នេហាគឺការឈឺចាប់ អត្ថន័យពិតនៃស្នេហាគឺកាស៊ូទ្រាំនិងការឈឺចាប់, តែបើចេះតែទ្រាំទៅរហូតស្លាប់ខ្លួនក៏មិនកើតដែរ ។

-ខ្ញុំសង្ឃឹមតិចណាស់ថាបានជួបមុខគ្នាយូរ ហើយញញឹមឱ្យបានយូរ ...

ខែប្រាំងទឹកស្ទឹងនៅតែហូរកាចច្រាំង ចុះភក្តីចិត្ត ម៉េចមិនហូរហៀរដូចទឹកស្ទឹងផង ?

-អាស្រីបងស្នេហ៍អូនគ្មានគ្រាហ៍អវសាន្តទេ តែដូចម្ដេចអូននៅតែចង់ឈ្នះបងយ៉ាងនេះ ? អត់សង្ឃឹមទេ បងសូមលាអូនយកប្រពន្ធហើយ !



## កាត់ខងស្ទួតដោតខង់ក្រពើ

**ខ្ញុំ** សូមសារភាពប្រាប់ប្រុសបង

**ឈ្នះ** រឿងកន្លងលំអងទុក្ខ

**ខ្ញុំ** អភ័ព្វស្នេហ៍ព្រាត់ឪពុក

**ចាញ់** លែងងើបមុខឃ្លាតប្រុសថ្លៃ ! ។

កម្លោះចិត្តពេលនេះលែងឈ្មោះជាកម្លោះទៀតហើយ ព្រោះគេបានរៀបការមួយអាទិត្យរួចមកហើយ ។

អាស្រីក៏ឆ្លៀតទៅមើលមុខបងថ្លៃស្រីដល់ទីលំនៅ ។ ម្ដងនេះគេឃើញនាងស្គមចម្លែកខុសធម្មតា ភក្ត្រាស្លឹតស្លក់ អាក្រក់ណាស់ នាងច្បាស់ជាកើតទុក្ខរឿងអ្វីមួយហើយ ។

មែននាងកើតទុក្ខស្នេហា !

មកដល់វេលានេះ ទើបយើងដឹងថាបេះដូងនាងលែងស្រោបដែកទៀតហើយ ។

នាងនៅមានចិត្តស្រឡាញ់កវីចិត្តណាស់ តែហេតុតែនាងចង់ឈ្នះនិងអៀនខ្មាស់ មិនព្រមប្រាប់ទើបក្លាយទៅជាយ៉ាងដូច្នេះ ។

ឯបុរសចិត្តព្រាត់ទៅក៏មិនបានដឹងថា សង្សារខ្លួននៅមានចិត្តភក្តីសោះទេ ។ គេឃ្លាតទៅថែមទាំងនាំចិត្តស្អប់ទៅផង ។

ឃើញពេលវេលាហុចឱ្យ ស្រីតូចលួចហុចសំបុត្រដ៏វែងមួយ ដើម្បីសារភាពប្រាប់ប្រុសស្នេហ៍អំពីកំហុសរបស់នាង ។

សំបុត្រនោះមានន័យជាអាទិ៍ ដោយសង្ខេបថា :

ការដែរព្រាត់គ្នានេះ មិនមែនមកពីម្ដាយអូនទេ មានគ្រួសារមួយទៀត ញុះញង់បង្ខំឱ្យអូនបដិសេធប្រកែកតែអូនមិនដឹងថា នេះជាកលឧបាយសោះ អូននៅស្រឡាញ់បងខ្លាំងណាស់ សូមបងឈប់ចោទអូនឈប់ហៅថាកាកីទៅ ។ អូនសូមប្រាថ្នាកើតជាតិក្រោយ ឱ្យយើងបានជួបគ្នាតែកុំឱ្យមានសាច់ឈាមជាញាតិជិតពេកដូចជាតិនេះ ។

កវីអាណិតសង្សារស្រីតូចស្រងេះស្រងោចម្នាក់ឯង មិនស្មានថារឿងនេះវាក្លាយជាយ៉ាងដូចច្នេះសោះ ?

សេក្ដីក្នុងសំបុត្របណ្ដាំ នាងថានៅចាំគ្រប់ជាតិនាងប្រើពាក្យសុទ្ធតែប្ដីចិត្ត, ម្ចាស់ចិត្ត ពេលនេះហើយដែលយើងឃើញចិត្តក្លាយខ្លួនទៅជាបុរសដំណើបលាយបាយខ្សាយ ។

ថ្ងៃចូលឆ្នាំខ្មែរខែមេសា ...

ប្ដីរ៉ានីឬមាណពចិត្ត ឥតបាននាំភរិយាខ្លួនទៅផ្ទះអតីតសង្សារឯច្បារអំពៅទេ ។ គេទៅតែម្នាក់ឯង ។

ញាតិមិត្របងប្អូននាំគ្នាសប្បាយ ហៅកញ្ច្រៀវលេងល្បែងគ្រប់ជំពូកតាមប្រពៃណីខ្មែរ ។

ប្លែកតែអាស្រីមិនឃើញនៅផ្ទះសោះ រសៀលបន្តិចទើបនាងត្រឡប់មកវិញទាំងស្រពោន !

ចិត្តសួរនាងស្រី :

-អាស្រីទើបមកពីណា ?

-ចាំ ទើបមកពីផ្ទះលោកគ្រូ គាត់ហៅទៅញ៉ាំបាញ់ឆែវ !

ជាលើកទីមួយហើយ ដែលគេឮអាស្រីឆ្លើយទៅចិត្តថាចាំ :

-ឯងខំមកលេងគេ គេទៅឯណាឯណោះ !

-ចុះម្សិលម៉ិញមិនឃើញមក ខ្ញុំស្មានថាបងមិនមកបានជាចេះតែដើរលេងទៅ ព្រោះម្សិលម៉ិញបងប្រុសមក បងមិនមក ។ នេះជាលើកទីមួយទៀត ដែលគេឮស្រីតូចនិយាយពាក្យបង ... ។

-អាស្រី រឿងយើងវាចប់ទៅហើយ ! នេះមកពីអូនឯងចង់ឈ្នះបងពេក បើកុំតែបងរៀបការក៏អូនឯងមិនសារភាពដែរមែនទេ ?

-ចិត្តយល់ច្រឡំហើយ ! ការពិតខ្ញុំគ្រាន់តែឆ្លើយថា មិនព្រមពីថ្ងៃនោះមក ខ្ញុំលេបបាយលាយទឹកភ្នែករាល់ថ្ងៃ ។ ខ្ញុំសរសេរសំបុត្រមួយទុកឱ្យចិត្តឯង តែមិនឃើញបងមកសោះ ហើយសំបុត្រត្រូវមានគេលួចមើល ខ្ញុំក៏ហែកចោលទៅ !

-ឥឡូវឱ្យបងធ្វើម៉េចទៅ បងពិបាកចិត្តណាស់បងចង់តែស្លាប់ទេ !

ក៏ជាលើកដំបូងដែរ ដែលចិត្តប្រើពាក្យថាបង ។

-ណ្ហើយចិត្ត ! ជាតិនេះខ្ញុំអភ័ព្វណាស់ព្រាត់ប៉ាជាទីស្រឡាញ់ឥឡូវមកថែមព្រាត់ប្រុសជាទីស្រឡាញ់ទៀត ជាតិក្រោយសូមយើងជួបគ្នាជាតិនេះយើងមានកម្មពៀរ បានជាយើងជួបគ្នាត្រឹមឈ្មោះជាសង្សារតែប៉ុណ្ណោះ ។

-បងស្ដាយណាស់ ស្ដាយដោយអូនមានះពេក បើថ្ងៃមុនគ្រាន់តែប្រាប់បងមិនមែនម៉ាក់ទេ ជាអ្នកបញ្ចេះឱ្យបងអស់សង្ឃឹមអីតែមិនព្រមសោះ ហ្នឹងហើយដែលគេហៅថាសើចស្ទើយំបន្លំស្ទើមែននោះរំពឹងអីជាតិនេះក្រោយជាតិដែលមើលមិនឃើញ ។

-បងម៉េចមិនមើលសៀវភៅរឿងជំនោរប៉ៃលិនរបស់លោក គង្គ ប៊ុនឈឿន !

-ណ្ហើយកុំទៅជឿរឿងប្រឌិតនោះ !

-ទេរឿងនោះគួរសង្សារគេចាំជាតិណា៎ !

គេនៅមានចិត្តស្មោះនិងសង្សារឥតប្រួលប្រែ ចំណែកខ្ញុំក៏អញ្ចឹងដែរ នៅតែស្រឡាញ់បងឥតក្បត់តែធ្វើម៉េចបើវាហួសអញ្ចឹងហើយជាតិក្រោយកុំឱ្យយើងជាប់សាច់ញាតិជិតពេក ព្រោះតែពាក្យថាបងប្អូន, ព្រោះតែស្ដាប់គ្រួសារ ទើបខ្ញុំក្លាយខ្លួនស្រីកំព្រាមួយចប់ បងឃើញទេពេលនេះបងបានសុខហើយ តែអូនវិញឱបទុក្ខសោការហួតថ្ងៃស្លាប់ ...

-ទេបងទេតើដែលត្រូវស្លាប់យ៉ាងអភ័ព្វ ព្រោះបងវេទនាចិត្តណាស់បងស្ដាយណាស់បើមុនរៀបការអូនហៅបងតែមួយម៉ាត់ ឬឆ្លើយចាំតែមួយម៉ាត់ មិនទៅការទេ ។ ម្ល៉េះសមចូលឆ្នាំនេះ បងមានសង្សារមួយស្អាតសោភា តែចេះបែរជាមានប្រពន្ធមួយ ដែលបងមិនស្រឡាញ់ទៅវិញ ។

-ចុះម៉េចក៏បងទៅការ ?

-ម៉ែទេតើ !

អូនទឹកបន្តិចទៅ ម៉ែស្រឡាញ់អាស្រីដែលជាក្មួយគាត់ប៉ុណ្ណា ? តែម៉ែក៏អស់សង្ឃឹមប៉ុណ្ណោះដែរ គាត់ក៏ដាច់ចិត្តដណ្ដឹងប្រពន្ធឱ្យបង ... ហ៊ឹ បងពិបាកចិត្តណាស់ ។

-អូនខុសហើយបង នេះជាកំហុសអូនទេ !

-មុននិងអូនឆ្លើយថាខុស

អូនបានធ្វើឱ្យបងយំរួចមកហើយមុននិងអូនស្គាល់ទុក្ខ អូនបានឱ្យបងដេកអោបទុក្ខឯកំពង់ចាមរាប់ខែមកហើយ លុះពេកបងក្លាយខ្លួនជាពលទាហាអភ័ព្វទៅហើយទើបអូនឆ្លើយថានៅស្ម័គ្រស្រឡាញ់ !

## សែនស្តាយថ្នាល់ស្តាំ

បទភ្លេងទំនុកច្រៀង ច្រៀងដោយ

គង្គ ប៊ុនឈឿន (BLUE) ស៊ីន ស៊ីសាមុត

ផ្តើមនិយាយ : ក្រោយពេលរៀបការ ទើបអូនឆ្លើយថាស្ម័គ្រ ...

ហ៊ឺ...សែនស្តាយណាស់ ! សែនស្តាយថ្នាល់ស្តាំ

១- ចាស់ទុំចូលស្តីស្រីអូនប្រកែក ទ្វីបលោករហែក បេះដូងយំស្រែកព្រែកព្រាត់គង្គា បង្គងព្រាត់សេកមេឃព្រាត់ចន្ទ្រា សិង្ហពាក់ស្បែកលាឥសីក្លាយជាអ្នកសង្គ្រាមជ័យ ។

២- បងកាត់ទងសួតដោតទង់ក្រពើ ថ្នាល់ស្តាំថ្នាល់លើ មន្តស្នេហ៍ព្រៃលើក្រោមខ្ចីមនិស្ស័យ លុះបងរៀបការទើបថាអាល័យចោទទាំងគ្មានន័យ ថាបងប្រល័យ ស្នេហ៍អូនគ្មានស្តាយ ។

R- ហួសហើយ ហួសហើយព្រលឹង ថ្នាល់ធ្លាប់ក្រេបក្រោមជ្រៃមាត់បឹង មិនអាចថ្លឹងស្មើពាក្យម្តាយ ផ្លូវស្នេហ៍សាងទុកកប់រូបកាយ បងនិងឆោមឆាយ ឥឡូវប្រែក្លាយជាផ្លូវអប្រិយ៍ ។

៣- បងសែនរន្ធត់ចង់ដុតរោងការ វិលរកជីវ៉ាក្រេបរសស្នេហាថ្នាល់ស្តាំជាថ្មី តែទាស់មនុស្សយើងគេយកសម្តី បងសូមលាស្រីរៀបការក្នុងន័យកេរ្តិ៍ឈ្មោះគ្រួសារ ។

ស្រីតូចតបទាំងអួលណែនបំពង់ក :

-បងជេរអូនចុះ បងជេរឱ្យអស់ចិត្តធ្វើម៉េចថ្ងៃនោះ ខ្ញុំមិនបានយកទ្រីស្តីគិតមុនគួរមកពិចារណា !

ខ្ញុំយកគ្រួសារជាធំ ភ្លេចសុភមង្គលខ្លួនឯង ខ្ញុំស្តាយណាស់ស្តាយសម្តីប៉ាណាស់ !

-អូននៅចាំពាក្យពូដែរហ៎ ?

បងមិនជេរអូនទេអាស្រី បងមានតែអាណិតនិងស្រឡាញ់អូនថែមទៀត តែអូនទេតើដែលមិនអាណិតបងសោះ បើបងបានជាជ្រុលមានប្រពន្ធហួសហើយ អូនកុំសម្លាប់បងដោយព្រមទទួលយកអាពីរនាក់ទៀតនោះណ៎ា ។

អូនមិនអាចប្រហារបងបានទេ បងទុកចិត្តចុះបើកាលៈទេសៈតម្រូវបង្ខំឱ្យអូនព្រមយកពួកគេអូនស៊ូរត់ចោលស្រុក... អូនមិនព្រមជាដាច់ខាត ។ ម៉េចបងពេញចិត្តទេ ?

-ហ៊ឺ បងនៅតែមិនអស់ចិត្តសោះ !

-ពីមុនម៉េចអូនមិនព្រមប្រាប់បង ?

ស្រីតូចពោលតប :

-អូនចង់ឈ្នះមើល តើយើងពីរនាក់នរណារៀបការមុន !

-ឥឡូវអូនឈ្នះហើយមែនទេ ?

-តែបងអើយ យកឈ្នះមកធ្វើអីបើលទ្ធផលវាបានបងជាការព្រាត់គ្នាដូច្នេះ !

-បន្តិចទៀតបងបើមិនស្លាប់ដោយស្គម ក៏ស្លាប់ដោយវិកលចរិកដែរ ...

-ឥឡូវនេះ ទើបខ្ញុំដឹងថាខ្ញុំខុសជាលើកទីពីរទៀតហើយ !

-ខុសរឿងអីទៅ ?

-បើខ្ញុំទ្រាំនៅស្ងៀមបៀមទុក្ខម្នាក់ឯងទៅ, ក៏បងមិនរារែកក្នុងចិត្តអញ្ចឹងដែរ តែនេះហេតុដែរតែអូនចង់សារភាពកុំឱ្យបងយល់ច្រឡំចោទអូនទទេៗ ...

នាងឈប់បន្តិច :

-អូ៎ ភ្លេចប្រាប់បង !

ក្រោយពេលដែលខ្ញុំឆ្លើយបដិសេធ មិនព្រមយកបង លោកសាស្ត្រាចារ្យអត់ប្រាក់ខែនោះ មកញ៉ែរាល់ថ្ងៃផ្ញើសំបុត្រមកសុំស្នេហ៍សុំកន្សែងពណ៌ផ្កាឈូក ម្ដងពណិស ។ ដល់យូរទៅមកសុំខ្ញុំមានប្រពន្ធជាអ្នកគ្រូ ដែលទើបប្រឡងជាប់ថាមានឡានជិះឯណា។ ខ្ញុំថាយកឯណាយកទៅគ្មានទាក់ទងអ្វីនិងខ្ញុំទេ ហើយមិនដឹងយ៉ាងម៉េច !

ស្រាប់តែពីថ្ងៃនោះមកបាត់ស្រមោលរហូត លែងមកឈរជ្រែងយកឡូយទៀតទៅ !

-អាស្រី ការជួបហើយព្រាត់ ព្រាត់ហើយជួបជាការធម្មតារបស់មនុស្សទូទៅ ... បើអូនយល់ថា ការឃ្លាតនេះមិនមែនជារូបយើងទេដែលជាមានចិត្តចង់នោះ ក៏គួរតែអូនវិលវិញ ។

អូនដឹងទេ គេអាចលុបតែអក្សរបាន តែគេមិនអាចលុបស្នាមអនុស្សាវរីយ៍បានទេ ។ ETAT CIVIL គេអាចលុបបានប៉ុន្តែគេមិនអាចលុបអ្វីនៅក្នុងបេះដូងបានទេណា៎ !

-អូនពិបាកចិត្តណាស់បង, ធ្វើម៉េចជាតិនេះហួសទៅហើយមានតែការស្ដាយក្រោយតែប៉ុណ្ណោះ ។

បុរសបើកភ្នែកពោលតប :

-បងដឹងហើយ ចិត្តអាស្រីឯងជាខ្មាំងតាមផ្ដន្ទាបងគ្រប់ជំហាន។ សូម្បីតែបងមានប្រពន្ធហើយរស់សុខហើយ ក៏នៅតែតាមព្យាបាទដែរ តើឱ្យបងស្លាប់ឬរស់ ? អូនឯងជាឆ្មាទះកណ្ដុរសម្លាប់ទើបថាអាណិត ...

-បងជេរអូនឱ្យច្រើនជាងនេះទៀតមក អូនព្រមទទួលកំហុសទាំងអស់ ! អូនសុំតែម្យ៉ាងសូមបងកុំប្រើឈ្មោះកាកីសោភីនី ស្រីចិត្តចើកតទៅទៀត !

-ហើយអូននៅតែឈ្មុះបងរហូតទៅ ?

-មែនអូនឈ្នះ !

~៩~

## ព្រោះនាងមានប្ដី

សូម ស្រស់ជីវ៉ាមេត្តាបង

កុំ មកស្នេហ៍ស្នងខុសមាត្រា

ឱ្យ ញាតិសន្ដានសើចនិន្ទា

ជួប ឥតគ្នីគ្នាជួយដឹងឮ ?

តាំងពីរៀបការមក ចិត្តមិនសូវទទួលបានការស្រណុកក្នុងចិត្តប៉ុន្មានឡើយ ។ ពិតមែនតែភរិយាគេចេះថ្នាក់ថ្នមគាប់ប្រសើរណាស់ដែរ ប៉ុន្តែអំណាចនៃមន្តស្នេហ៍អតីតកាលចេះតែមកលងអារម្មណ៍គេជានិច្ច។

ថ្ងៃមួយនោះគេជញ្ជឹងគិតថា រឿងរ៉ាវដែលនាំឱ្យរូបគេនិងអាស្រីបែកគ្នានេះ

មិនមែនជារឿងដែលកើតឡើងដោយចៃដន្យនោះព្រោះអាស្រី ក៏បានផុសរឿងនេះខ្លះៗដែរ ថារឿងនេះកើតចេញមកពីគំនិតខ្មៅក្រខ្វក់របស់នាយទូច ដែលជាគូប្រជែងស្នេហ៍របស់គេតាំងពីដើមមក ។

តាមពិតនាយទូចហ្នឹង ក៏ជាបងប្អូនជីដូនមួយនិងអាស្រីដែរ ប៉ុន្តែសាច់ខាងម្ដាយ ហើយក៏ជាបងប្អូននិងចិត្តដែរ ប៉ុន្តែចិត្តនេះខាងខ្លាចលោកសំណាង ។

ចិត្តដឹងច្បាស់ថា នាយទូចបានខិតខំរកមធ្យោបាយគ្រប់បែបយ៉ាង

ដើម្បីទាញអាស្រីពីរូបគេ... មិនឱ្យបានគេ... សូម្បីតែនាយទូចខ្លួនឯងហ្នឹង រៀបការនិងនារីផ្សេងទៅហើយក៏ដោយ ។

ទូចតាំងស្មារតី នៅក្នុងអាការឈ្នានិះព្យាបាទដោយលាក់មុខ គឺថា បើអាស្រីមិនព្រមយកខ្លួនទៅហើយ អាស្រីក៏មិនតោងបានទៅរបស់ចិត្តដែរ ។

កាលបើមមៃនឹកឃើញរឿងចាស់បែបហ្នឹងហើយ ទើបចិត្តនឹកស្តាយក្រោយជាខ្លាំង ដែលមិនគួរអាស្រីទៅជឿតាមពាក្យអុជអាលចាក់រុកនាយទូច រហូតដល់ប្រកែកមិនព្រមទទួលស្គាល់ពាក្យដណ្តឹងរបស់ម្តាយសោះ ។ ប៉ុន្តែឥឡូវនេះស្អី១ ក៏វាជុលហួសអស់ទៅហើយ !ទោះបីជាគេទៅតាមសងសឹងនាយទូចនោះវិញ ក៏វាជាការឥតអំពើដែរគេប្រគល់កិច្ចការនេះឱ្យទៅតុលាការនៃព្រហ្មលិខិតចាត់ចែងកត់ត្រាសំណុំរឿង និងកាត់សេចក្តីនាយទូច ដែលមានគំនិតលំអៀង ក្នុងរឿងស្នេហានេះផងចុះ ។

...ព្រហ្មលិខិត ក៏ដូចជាជួយចាត់ការក្នុងរឿងនេះដែរ គឺបានទម្លាក់ទោសឱ្យនាយទូចមានប្រពន្ធ តែប្រពន្ធមានចិត្តត្រេកត្រអាលស្រើបស្រាលហួសហេតុ។

ល្ពឹកណានាយទូច នៅជិតដិតស្និតស្នាលជាប់ជានិច្ចនោះ ទើបបានសុខសាន្ត តែបើប្រែជានាយទូចមានការរវល់ទៅឆ្ងាយយូរ មុខជានាងភរិយានោះ ដូចតែចេះរមាស់ដួងចិត្ត ចេះតែមើលឃើញប្រុសដ៏ទៃស្អាតជាងប្តីខ្លួនឯងជានិច្ច។

...ពេលមួយនោះ ទូចចេញទៅធ្វើការបាត់ នាងស៊ីនួន ជាភរិយានៅចាំផ្ទះជាមួយកូនតូច ដែលទើបមានអាយុ ១៥ខែ ស្រាប់តែចិត្តទៅលេងព្រោះមានការពិសេសមួយដែលចង់ជួប ។

ក្រោយពីសំណេះសំណាលគ្នាលេងពីនេះពីនោះ ចិត្តក៏រៀបរាប់លានាងស៊ីនួនមកផ្ទះវិញដោយពោលថា :

អ៊ីចឹងខ្ញុំគិតលាស៊ីនួន ត្រឡប់ទៅសិនហើយ ចាំខានស្អែកសឹមមកជួបនិងទូច... ខ្ញុំមិនដឹងថាគេមិននៅផ្ទះយ៉ាងនេះសោះ !

ស៊ីនួនចេះតែលួចសម្លឹងមកលើសម្ផស្សកាយរបស់ចិត្តដោយលេបទឹកមាត់ក្អឿក១ ទើបវាចារ :

ប្រញាប់អីម្ល៉េះបងនៅអង្គុយលេងសិនហើយ...បងឯងមិនដែលមកលែងគ្រាន់តែមកមួយភ្លែតក៏ប្រញាប់ទៅវិញភ្លាម ធ្វើអ៊ីចឹងដូចជាស្អប់ខ្ញុំណាំ ! ...

ចិត្តក៏អង្គុយលេងបន្តិចទៀត ជួនពេលនោះស្រាប់តែគេឃើញស៊ីនួនស្ទុះចូលទៅរៀបចំខ្លួនប្រាណយ៉ាងស្អាត
ជាហេតុធ្វើឱ្យចិត្តមានសេចក្តី ឆ្ងល់ក៏សួរ :

-ស៊ីនួនរៀបចំខ្លួនគិតទៅណាហ្នឹង ?

ស្រីស្រស់ពោលយ៉ាងញញឹម :

-តាំងពីយូរណាស់មកហើយ ខ្ញុំមិនដែលបានដើរលេងជាមួយបងម្តងសោះ ពេលនេះខ្ញុំចង់សុំបណ្តើរបងម្តង !

-និយាយថាម៉េច... បណ្តើរអ្នកណា ?

ស៊ីនួនតបយ៉ាងស្រស់ :

-បណ្តើរបងឯងនិងណាំ ខ្ចីបណ្តើរម្តងមិនបានឬ... ខ្ញុំចង់ឱ្យបងជូនខ្ញុំទៅមើលកុន ទៅញ៉ាំបាយនៅផ្សារចាស់ ខ្ញុំអផ្សុកណាស់នៅផ្ទះត្រម៉ោចត្រម៉ង់តែម្នាក់ឯងដូច្នេះ ?

ចិត្តឮដូច្នេះដូចមិនស្រួលសោះ :

-ស៊ីនួន... ម៉េចក៏មកបបួលខ្ញុំទៅវិញ... ម៉េចក៏មិនបបួលទូចដែលជាប្តីហ្នោះ ?

-ហ៊ឺ ... តាំងពីរៀបការមក បងទូចមិនដែលបបួលខ្ញុំដើរលេងឯណាម្តងទេ ... ខ្ញុំអផ្សុកសឹងស្លាប់ ... ហើយក៏មិនប្រសព្វធ្វើឱ្យខ្ញុំសប្បាយចិត្តផង ... ទៅបងចិត្ត ចាំអីទៀត ខ្ញុំរៀបចំខ្លួនហើយ !

ចិត្តនៅតែប្រកែកញ៉ាញ :

-ទេ ! ...ដូចជាមិនស្រួលទេដឹងស៊ីនួន !

-បងឯងខ្លាចអី... យើងសុទ្ធតែមានប្តីមានប្រពន្ធរៀងខ្លួនហើយតើ ! ...ខ្ញុំធ្លាប់មើលសៀវភៅឃើញគេធ្វើបែបហ្នឹងតែសន្ធឹក ...

ចិត្តនឹកអស់សំណើច :

-ស៊ីនួនធ្វើយ៉ាងហ្នឹង មុខជាចង់ឱ្យទូចវាយករឿងនិងខ្ញុំហើយ ខ្ញុំយល់ហើយថា ទូចវាប្រច័ណ្ឌណាស់ មិនតែប៉ុណ្ណោះវាស្រឡាញ់ ស៊ីនួនឯងណាស់ ... កាលណាវាមកទាន់ឃើញខ្ញុំបណ្តើរស៊ីនួនឯងមុខជាវាចោទខ្ញុំថាយ៉ាងម៉េចៗ ហើយ !

-ឱ្យគេចោទខ្លះៗទៅចុះ ជឿថារស់នៅលើផែនដីនេះជៀសផុតទឹកភ្លៀងឬ ម្យ៉ាងទៀតបើគេយល់ថាស្រឡាញ់គ្នានិងបងមែន កាន់តែប្រសើរណាស់ទៅទៀត ព្រោះតាមការពិតចិត្តអ៊ីចឹងមែន !

ចិត្តឮដូចច្នេះស្ទើរជ្រុះវែនតាពីភ្នែក :

-ហ៊ឺ ... ក៏ស៊ីនួនឯងថាអ៊ីចឹង ?

ស្រីស្រស់សើចកក្បោក :

-អីក៏របស់ភ័យម្ល៉េះហ៎ ! ... គ្រាន់តែបណ្តើរជូនខ្ញុំទៅលេងមួយពេលមានទាស់ខុសអី លុយកាក់លើខ្ញុំចេញទេតើ ...

ចិត្តខំសម្រួលអារម្មណ៍វិញ :

-ខ្ញុំមិនហ៊ានទេ ... ព្រោះស្រុកខ្មែរយើងមានប្រពៃណីជាលក្ខ គោលណាំ យើងធ្វើអ្វីស្រេចតែចិត្តពេកទៅមិនខ្លាចក្រែងរអែងចិត្តខ្មែរដូច គ្នាខ្លះនោះ ក៏វាមិនកើតដែរ ម្យ៉ាងទៀតមនុស្សយើងធំនិងកិត្តិយស កាល ណាអ្នកជិតខាងគេនិន្ទាពេបជ្រាយឱ្យយើង តើកិត្តិយសរបស់យើងទៅជា យ៉ាងណា បើចង់ដើរលេងម៉េចមិនឱ្យឈ្នួលបំរើជូនទៅ ? ...

ស៊ីនួនធ្លាក់ទឹកមុខស្រពោន :

-ខំតែងខ្លួនស្អាតម្ល៉ឹងៗ ទៅដើរលេងជាមួយឈ្នួលតើសក្តិសមឬ... សមតែដើរជាមួយបងឯង ចេញចូលញ៉ាំក្នុងហាងធំៗ... ដល់យប់សឹម ត្រឡប់មកវិញ !

ជួនពេលដែលស៊ីនួននិយាយនោះ ទារកដែលនៅលើអង្រឹងក៏ ស្រែកយំរំវាំងឡើង ជាហេតុធ្វើឱ្យចិត្តមានឱកាសពោលទៀត :

-ហ្ន៎...ឃើញទេ...កូនយំបែបនេះចង់ទៅដើរលេងផងឬ...បានអ្នក ណាឱ្យទឹកដោះវាបៅ ? ស៊ីនួនដើរទៅអង្រួនកូនបណ្តើរទើបឆ្លើយ :

ឆោតអីម្ល៉េះទេបង... យើងមានលុយ ទោះបីជាមានកូនវាល់ កញ្ជេរក៏វាមិនពិបាកដែរ ជួលតែឈ្នួលឱ្យវាមើល បំបៅទឹកដោះគោបញ្ចុក បាយចំណីទៅក៏វារួចគ្នាទៅហើយ... ម៉េចបងយល់ថាគ្រាន់តែកូនមួយហ្នឹង ពិបាកណាស់ទៅឬ ចិត្តយកដៃអេះក្បាល :

-សម្រាប់បងសូម្បីតែកូនមួយចំហៀង ក៏វាពិបាកដែរ ពិសេស ទៅទៀតបងមកនេះក៏មិនបានតាំងចិត្តថានិងដើរលេងជាមួយស៊ីនួនដែរ សូមស៊ីនួនបំភ្លេចអារម្មណ៍ផ្តេសផ្តាសនេះចោលទៅ ! ... កុំឱ្យអ្នកផងគេ សើចណាំ !

ស៊ីនួននៅតែមិនអស់ចិត្ត :

-ឥឡូវដើម្បីកុំឱ្យគេដឹង... ខ្ញុំទៅចាំបងនៅឯផ្សារចាស់មុន... ហើយបងទៅតាមក្រោយ !

ចិត្តនៅតែប្រកែក :

-អីចឹងវាឡាតែក្តួច... ស្រួលគឺកុំទៅតែម្តង ឱ្យបងសុំចិត្តទៅចុះ បងមិនមែនស្អប់ខ្ពើមទេ ... ទូចក៏វាបងប្អូនជីដូនមួយនិងបងដែរប៉ុន្តែកាល ដែលស៊ីនួនមកបង្ខំចិត្តបងឱ្យដើរលេងខុសទម្លាប់ដូច្នេះវានាំឱ្យមាន គ្រោះ ថ្នាក់ណាំ ...

-ហ៊ឺ ... ពិបាកនិយាយណាស់... ប្រុសអីមានភ្នែកដល់ទៅបួនតែ មានចិត្តតែមួយ !

-អីចឹងហើយ... ចិត្តបងមានតែមួយ សម្រាប់ប្រគល់ឱ្យភរិយា បងប៉ុណ្ណោះ !

ស៊ីនួនមួម៉ៅពេកក៏ស្ទុះទៅបើកវិទ្យុខ្លាំងៗ ដើម្បីបន្លប់ទុក្ខ ។ ជួន

ពេលនោះក្នុងវិទ្យុក៏ផ្សាយដល់នាទីបទចម្រៀង ដែលដកស្រង់ពីថាស

ហើយប៉ះលើបទដែលមានចំណងជើងថា :

**ព្រោះនាងមានប្ដី**

បទភ្លេងទំនុកច្រៀង ច្រៀងដោយ

គង្គ ប៊ុនឈឿន （BOLERO SURF） អ៊ិត ណារី និង

រស់ សេរីសុទ្ធា

ស្រី- នែ ប្រុសឆើតរូបឆោមល្អឯក គន់ជាប់ភ្នែកចម្លែកពីប្រុសដទៃបើបាន

បណ្ដើរមួយថ្ងៃ មើលកុនល្ខោនអាយ៉ៃ មិនដឹងសប្បាយយ៉ាងណា ? ។

ប្រុស- មិនហ៊ានទេព្រោះនាងមានប្ដី មានកូនខ្ចីហើយប្ដីចេញទៅធ្វើការបើ

កូនយំបាននរណា និងបញ្ចុកអាហារឱ្យទឹកដោះគោវាបៅ ? ។

R ស្រី- បងកុំគិតឆ្ងាយ មានប្រាក់ចាយជួលឈ្នួលឱ្យមើលកូនទៅ

ប្រុស- ក្រែងនាំអាស្រូវ បងមិនទៅដើរលេងជាមួយស្រីទេ ។

ស្រី- យី ! ...ប្រុសនេះមិនស៊ីវីឡ័យ ដើរមិនទាន់សម័យពួកស្រីយេយេ?...

ចម្រៀងនេះចប់ស្ទើរមិនទាន់ ស៊ីនួនក៏ស្ទុះទៅបិទគិប ! ហើយរអ៊ូ

ថា :

-ហ៊ឺ... សូម្បីតែអារ៉ាឌីយ៉ូក៏មិនចូលជើងជាមួយឯងដែរ !

ចិត្តសើចឃឹកៗ :

-ឃើញទេ... ការដែលខុសនិងប្រពៃណី សូម្បីអ្នកកវីនិពន្ធក៏មានចងទុកក្នុងបទភ្លេងជាមាត្រាដែរ... ណើ្ហយចាំប្ដីមកសឹមបបួលគ្នាទៅដើរលេងចុះ ... ខ្ញុំសុំលាទៅវិញហើយ !

ពោលរួច ចិត្តក៏លាស៊ីនួនត្រឡប់ទៅផ្ទះវិញទាំងនឹកអស់សំណើចក្នុងចិត្ត ។ មួយអាទិត្យក្រោយចិត្តក៏បានទៅជួបនិងអាស្រីម្ដងទៀត... គេទៅលានាងព្រោះគេត្រូវឃ្លាតទៅសមរភូមិមួយដ៏សែនឆ្ងាយ ។ នៅពេលនោះអាស្រីក៏បាននាំដំណឹកល្អមួយមកប្រាប់គេដែរ :

-បងមិនដឹងថាឥឡូវទូចនិងស៊ីនួនលែងលះគ្នាទេឬ ?

ចិត្តបើភ្នែកធំៗ ដោយនឹកឆ្ងល់ :

-អាស្រីដឹងរឿងនេះពីណាមក ?

-មានគេប្រាប់ខ្ញុំច្បាស់, នេះហើយផលកម្មវាបំបែកបំបាក់យើង...

ចិត្តដកដង្ហើមធំ :

-ណើ្ហយកុំខ្វល់អីនិងរឿងគេ... តាមពិតស៊ីនួនក៏ជាស្រីដែលមានចរិកប្លែក មិនងាយប្រុសណាទ្រាំទ្របានទេ ! គិតតែរឿងយើងឯណេះវិញ ! ...

អាស្រីធ្លាក់ទឹកមុខស្រងូត :

-បងទៅឆ្ងាយ... យកប្រពន្ធបងទៅដែរឬ ?

-ទៅច្បាំង ... យកប្រពន្ធទៅជាមួយម៉េច បងយកតែក្តីនឹករលឹក ប៉ុណ្ណោះដែលជាទ្រព្យកំណប់ចិត្ត ទោះទៅដល់ក្រហែងណាក៏តែងនឹក ឃើញជានិច្ច !

-ស្អីទៅក្តីរលឹកហ្នោះ ! ...

-គឺនឹកដល់រូបអូននឹកដល់ថ្ពាល់ស្តាំដែលបងស្តាយ ! បងលាអូន ទៅស្អែកនេះហើយណា៎ !

**~ចប់~**

ច្បារអំពៅ ២៦ មិថុនា ១៩៧២

គង្គ ប៊ុណ្ណឿន

បទភ្លេង គង្គ ប៊ុណ្ណឿន

"របួសចាស់"

ទំនុកច្រៀង សុខ បណ្ឌិត

- រលកវាចា វេលាកន្លងមួយឆ្នាំឃ្លាតបង នួនល្អងប្រមាថ ពិភពវិលទៅពោរិលមារយាទ ហៃអើតាមញាតិ ស្រីជាតិកាកី ។

- គម្ពីរបេះដូងចោររូងលួចឆក់ ពេជ្រជាកញ្ចាក់សក់ជាសូតថ្មី ភ្លេច ផ្ទះភ្លេចពាក្យងាយចោលករី ម្តាយលក់កូនស្រីដូចលក់ដីភូមិ ។

R ទន្លេបាសាក់នៅហូរចាក់ព្រែក តែដីក្បត់ដែកផ្កាស្រែកក្បត់ឃ្មុំ មេឃមានពពក មកបាំងច័ន្ទខ្ញុំ ឱ្យរស្មីភ្នំក្លាយជាដីទួល ។

- សុក្រឃ្លាតហើយសៅរ៍នៅតែតាមខាំ ចិត្តស្មោះជាស្រាំចាំប្រែប្រួល របួសជាពុំងារដុតឈ្មួល អូនច្រាន បងដួលនិមលអោបដៃ ។